# ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

## វិទ្យាស្ថាន វ៉ាន់ដា

VANDA INSTITUTE

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធ

TAXPAYER INFORMATION UPDATE

## ជំនាញ គណនេយ្យ

**រាជធានីភ្នំពេញ-ឆ្នាំ២០២៤**

PHNOM PENH-2024

## ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

## វិទ្យាស្ថាន វ៉ាន់ដា

VANDA INSTITUTE


# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធ

TAXPAYER INFORMATION UPDATE


## សាស្ត្រាចារ្យណែនាំ៖ លឹម គន្ធា


## ជំនាញ គណនេយ្យ


**រាជធានីភ្នំពេញ-ឆ្នាំ២០២៤**

PHNOM PENH-2024

**គណៈកម្មការត្រួតពិនិត្យសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២១**

**ប្រធានបទ៖ ការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធ**

គណៈកម្មការវាយតម្លៃទី១

បេក្ខបណ្ឌិត ស្រេង ផល្លា

សាស្ត្រាចារ្យណែនាំ

លីម គន្ធា

គណៈកម្មការវាយតម្លៃទី៣

បេក្ខបណ្ឌិត យ៉ាក វុទ្ធី

គណៈកម្មការវាយតម្លៃទី២

បេក្ខបណ្ឌិត មាស សំណាង

ប្រធានគណៈកម្មការវាយតម្លៃ និងជាប្រធាន
មជ្ឈមណ្ឌលស្រាវជ្រាវ

បណ្ឌិត សេង សំអឿន

គណៈកម្មការវាយតម្លៃទី៤

បេក្ខបណ្ឌិត យ៉ែម សុខហៀក

**នាយកវិទ្យាស្ថាន**

**បណ្ឌិត ហេង វ៉ាន់ដា**

នាយិការងអចិន្ត្រៃយ៍

បណ្ឌិត ហ៊ូ គុជគន្ធលីនណា

# អារម្ភកថា

(Impression)

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យ នៅវិទ្យាស្ថាន វ៉ាន់ដា អស់រយៈពេល ៤ឆ្នាំ សិក្សារួចមក ក្រុមយើងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើន ដែលពាក់ព័ន្ធនឹងមុខវិជ្ជាគណនេយ្យ ជាពិសេស ក្រុមយើងខ្ញុំ បានយល់ច្បាស់ថាជំនាញគណនេយ្យ គឺជាជំនាញមួយដែលមានសារៈសំខាន់បំផុត សម្រាប់ទីផ្សារនាពេលបច្ចុប្បន្ន ក្នុងនោះមានស្ថាប័នរដ្ឋក្តី ឯកជនក្តី ឬអង្គការក្រៅរដ្ឋាភិបាលក្តី គឺសុទ្ធតែត្រូវអនុវត្តកិច្ចការគណនេយ្យដូចគ្នា។ ដោយឡែក ដើម្បីឱ្យការសិក្សារបស់និស្សិតកាន់តែមានគុណភាពខ្ពស់ វិទ្យាស្ថាន វ៉ាន់ដា បានបញ្ចូលនូវមុខជំនាញសំខាន់ៗ ដែលពាក់ព័ន្ធនឹងការងារគណនេយ្យតាមកម្មវិធីសិក្សា ដែលមានក្នុងឆ្នាំសិក្សាទី១ រហូតដល់ឆ្នាំសិក្សាទី៤។

គ្រប់មុខវិជ្ជាទាំងអស់ គឺសុទ្ធតែមានសារៈសំខាន់ក្នុងការត្រួសត្រាយផ្លូវនិស្សិត ឱ្យយល់ដឹងកាន់តែច្បាស់ ពីការអនុវត្តការងារគណនេយ្យ ពីការចាប់ផ្តើមរៀបចំផែនការ ការអនុវត្ត ការបញ្ចប់ និងត្រួតពិនិត្យវាយតម្លៃ ព្រមទាំងផ្តល់ជាអនុសាសន៍នៅក្នុងការងារគណនេយ្យ ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រងនៅក្នុងស្ថាប័នខ្លួន ក្នុងន័យឆ្លើយតបឱ្យបានល្អប្រសើរនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលបានដាក់ចេញ។ ដោយក្រុមយើងខ្ញុំ បានសង្កេតឃើញថាកិច្ចការងារមួយនេះ មានសារៈសំខាន់យ៉ាងខ្លាំងស្របពេលក្នុងការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្របានមកដល់ ទើបក្រុមយើងខ្ញុំ សម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយស្តីពី **"ការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធ"** យកមកសិក្សាស្រាវជ្រាវ នឹងចងក្រងក្នុងគោលបំណងឱ្យអ្នកសិក្សាស្រាវជ្រាវទាំងអស់ យល់កាន់តែស៊ីជម្រៅពីការសរសេរសារណា នឹងប្រសិទ្ធភាពនៃការប្រមូលពន្ធ នឹងការបង់ពន្ធ ។ ក្រុមយើងខ្ញុំសង្ឃឹមថា ការរៀបចំសារណានេះ នឹងបានចូលរួមចំណែកក្នុងការស្រាវជ្រាវកិច្ចការរបស់និស្សិតជំនាន់ក្រោយៗ ព្រមទាំងអ្នកស្រាវជ្រាវដ៏ទៃទៀត ដែលមានបំណងសិក្សាស្វែងយល់ពីកិច្ចការនេះ។

ជាទីបញ្ចប់ក្រុមយើងខ្ញុំ សូមមេត្តាខន្តី អភ័យទោស ពីសំណាក់លោកគ្រូ អ្នកគ្រូ រៀមច្បង និងអ្នកអានទាំងអស់ នូវរាល់កំហុសឆ្គងដែលកើតមានដោយអចេតនា នៅក្នុងសារណានេះ ហើយក្រុមយើងខ្ញុំរីករាយនឹងទទួលយករាល់ការរិះគន់ក្នុងន័យស្ថាបនា ដើម្បីឱ្យការរៀបចំលើកក្រោយទៀតមានភាពកាន់តែល្អប្រសើរ។

# រចនាសម្ព័ន្ធក្រុម



**លាង លីហ្សា**
ID: B21/1815



**ឌន លីណា**
ID: B21/1811



**អ៊ុង លក្ខិណា**
ID: B21/1248



**សប្បាយ សុភ័ក្ត្រា**
ID: B21/3447

# សេចក្តីថ្លែងអំណរគុណ

ក្រុមយើងខ្ញុំជានិស្សិតនៃ វិទ្យាស្ថាន វ៉ាន់ដា ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២១ ជំនាញគណនេយ្យ

**សូមសំដែងនូវការគោរពដឹងគុណ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ**

ក្រុមគ្រួសារដែលបានជួយឧបត្ថម្ភ គាំទ្រ ទាំងសម្ភារៈ ថវិកា និងស្មារតី ជំរុញលើកទឹកចិត្តដល់ក្រុមយើងខ្ញុំក្នុងការរៀនសូត្រ ដើម្បីទទួលបានចំណេះដឹងរហូតដល់សព្វថ្ងៃ។ ក្នុងនោះក្រុមយើងខ្ញុំសូមសំដែងនូវការគោរព និងកត្តញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុតដល់អ្នកមានគុណ ដែលបានផ្តល់កំណើតដល់ខ្ញុំបាទ នាងខ្ញុំគ្រប់រូប និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់បណ្ឌាសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ ទាំងអស់ដែលបានបណ្តុះបណ្តាលក្រុមយើងខ្ញុំនាពេលកន្លងមក។

ក្រុមយើងខ្ញុំ សូមសំដែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅដល់ឯកឧត្តមបណ្ឌិត ហេង វ៉ាន់ដា នាយកនៃវិទ្យាស្ថាន វ៉ាន់ដា ដែលបានផ្តល់ទីកន្លែងបណ្តុះបណ្តាល ព្រមទាំងផ្តល់បទពិសោធន៍យ៉ាងច្រើនដល់យើងខ្ញុំ។

សូមគោរពថ្លែងអំណរគុណចំពោះសាស្ត្រាចារ្យ **លឹម គន្ធា** ជាសាស្ត្រាចារ្យណែនាំដោយបានជួយជ្រោមជ្រែងបង្ហាត់បង្ហាញសព្វបែបយ៉ាង ដើម្បីជួយដល់ក្រុមយើងខ្ញុំបញ្ចប់កិច្ចការសារណានេះជាស្ថាពរ។

សូមគោរពថ្លែងអំណរគុណដល់សាស្ត្រាចារ្យ និងបុគ្គលិកនៃវិទ្យាស្ថានវ៉ាន់ដាទាំងអស់ ដែលបានខិតខំប្រឹងប្រែងក្នុងការបង្ហាត់បង្ហាញ លើកទឹកចិត្ត អនុគ្រោះដល់ក្រុមយើងខ្ញុំរហូតធ្វើឱ្យការសិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ឆ្លៀតក្នុងឱកាសនេះដែរ ក្រុមយើងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់បុគ្គលទាំងអស់ខាងលើឱ្យជួបតែពុទ្ធពរទាំងបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អំណះអំណាង

យើងខ្ញុំជានិស្សិតនៃវិទ្យាស្ថាន វ៉ាន់ដា ថ្នាក់បរិញ្ញាបត្រសិក្សា ជំនាន់ទី២១ ជំនាញគណនេយ្យ៖

សូមធានាអះអាងនឹងទទួលខុសត្រូវ លើខ្លឹមសារអត្ថបទនៅក្នុងសារណានេះថា សារណានេះ គឺជាស្នាដៃស្រាវជ្រាវផ្ទាល់របស់ក្រុមយើងខ្ញុំ ដោយគ្មានពាក់ព័ន្ធជាមួយសារណា ឬរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ ចំពោះទិន្នន័យលទ្ធផលនៃការស្រាវជ្រាវដែលមានក្នុងសារណានេះ។

ថ្ងៃ. ............... ខែ.......... ឆ្នាំ........... ព.ស.២៥៦....

ភ្នំពេញ ថ្ងៃទី.......ខែ...........ឆ្នាំ២០២៤

**ហត្ថលេខាតំណាងក្រុម**

# សេចក្តីសង្ខេបនៃការស្រាវជ្រាវ

ការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធ គឺសំដៅលើអ្នកជាប់ពន្ធដែលមានការផ្លាស់ប្តូរព័ត៌មានណាមួយដូចមានចែងឡើង ហើយតម្រូវឱ្យមកធ្វើបច្ចុប្បន្នភាពព័ត៌មានដោយត្រូវបំពេញព័ត៌មាន និងភ្ជាប់មកនូវឯកសារចុងក្រោយនៃឯកសារបញ្ជាក់ការផ្លាស់ប្តូរព័ត៌មាននោះតែប៉ុណ្ណោះ ដូចមានកំណត់ក្នុងពាក្យស្នើសុំចុះបញ្ជីពន្ធដារ និងបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ (ទម្រង់១០១ )។ នាពេលបច្ចុប្បន្ននេះ ការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធ គឺជាផ្នែកមួយយ៉ាងសំខាន់ក្នុងការជួយជំរុញក្នុងការចុះបញ្ជី ព្រោះវាក៏ជាផ្នែកមួយក្នុងការជួយអភិវឌ្ឍន៍ប្រទេសជាតិឱ្យមានតម្លាភាព និងមានភាពរីកកចម្រើនផងដែរ។

ដោយផ្អែកលើមូលដ្ឋាន ដែលជាកត្តាចម្បងនៅក្នុងការស្រាវជ្រាវ និងចងក្រងសារណាមួយនេះឡើងមក គឺចង់ស្វែងយល់ពីនីតិវិធីនៃការធ្វើបច្ចុប្បន្នភាព ការអនុវត្តទៅតាមលិខិតបទដ្ឋានដែលបានដាក់ចេញ ក៏ដូចជាសារៈសំខាន់នៃការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធផងដែរ។ បុគ្គលស្នើសុំធ្វើបច្ចុប្បន្នភាពព័ត៌មានត្រូវបំពេញ "ពាក្យស្នើសុំចុះបញ្ជីពន្ធដារ និងបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ (ទម្រង់ ១០១)" និងភ្ជាប់ឯកសារតម្រូវទៅតាមទ្រង់ទ្រាយគតិយុត្ត។ ដាក់លិខិតជូនដំណឹងទៅសាមីអង្គភាពគ្រប់គ្រង ឬនាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅដោយៈ បំពេញពាក្យស្នើសុំចុះបញ្ជីពន្ធដារ និងបច្ចុប្បន្នភាពព័ត៌មានរបស់អ្នកជាប់ពន្ធ (ទម្រង់១០១) នៅផ្នែកដែលមានព័ត៌មានត្រូវផ្លាស់ប្តូរ។ ក្រោយពេលទទួលបានការសម្រេចឱ្យចុះបញ្ជីពន្ធដារ ឬធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ រដ្ឋបាលសារពើពន្ធអាចចុះដល់ទីតាំងអ្នកជាប់ពន្ធ ដើម្បីប្រគល់ឯកសារផ្លូវការ ដែលបានចេញដោយរដ្ឋបាល សារពើពន្ធ និងពិនិត្យផ្ទៀងផ្ទាត់ចំណុចនិយាម ថតរូបទីតាំង និងកត់ត្រាទិន្នន័យទីតាំងផ្សេងៗរបស់អ្នកជាប់ពន្ធ ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធដារ។

បន្ទាប់ពីធ្វើការសិក្សាស្រាវជ្រាវ អំពីការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធរួចមក យើងខ្ញុំសង្កេតថា ដំណើរការនៃការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធ បានជួយជំរុញដល់យុទ្ធសាស្ត្រប្រមូលពន្ធរបស់រដ្ឋឱ្យមានប្រសិទ្ធភាព និងជួយដល់ការដោះស្រាយបញ្ហាសេដ្ឋកិច្ច ក៏ដូចជាជម្រុញក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ប្រទេសជាតិឱ្យកាន់តែរីកចម្រើនដូចជាៈ ស្ពានថ្នល់ សាលារៀន មន្ទីរពេទ្យ...។ ដូចគ្នានេះដែរការធ្វើបច្ចុប្បន្នភាពក៏បានជួយឱ្យសហគ្រាសមានការយល់ដឹង អំពីកាតព្វកិច្ចក្នុងការបង់ពន្ធជូនរដ្ឋ ក៏ដូចជាការធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសរបស់ខ្លួន។

សរុបសេក្តីមក ការយល់ដឹងអំពីការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធ ពិតជាមានសារៈសំខាន់ណាស់ក្នុងការគាំទ្រចំពោះយុទ្ធសាស្ត្រប្រមូលពន្ធ។ ដូច្នេះហើយ ទើបទាមទារឱ្យការផ្សព្វផ្សាយចំណេះដឹងនៃការបង់ពន្ធ ការចុះបញ្ជី និងការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធ ដល់ប្រជាពលរដ្ឋ ក៏ដូចជាសហគ្រាសឱ្យមានភាពទូលំទូលាយ ដើម្បីឱ្យការប្រមូលពន្ធមានភាពកាន់តែប្រសើរឡើង។

# មាតិកា

ទំព័រ

អារម្ភកថា ......i
របនាសម្ព័ន្ធ......ii
សេចក្ដីថ្លែងអំណរគុណ ......iii
អំណះអំណាង ......vi
សេចក្ដីសង្ខេបនៃការស្រាវជ្រាវ ......v

## ជំពូកទី១
## សេចក្ដីផ្ដើម

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ......១
១.២ចំណោទបញ្ហានៃការស្រាវជ្រាវ......១
១.ដើម្បីធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធតើត្រូវបំពេញឯកសារអ្វីខ្លះ ?......២
២.តើការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធមានសារៈសំខាន់អ្វីខ្លះ?......២
១.៣ គោលបំណងនៃការស្រាវជ្រាវ......២
១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ......២
១.៤.១ ទំហំដែនកំណត់ ......២
១.៤.២ វិសាលភាពនៃការស្រាវជ្រាវ......២
១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ......២
១.៥.១ ការប្រមូលទិន្នន័យបន្ទាប់ ......២
១.៦ សារៈសំខាន់នៃការស្រាវជ្រាវ......២
១.៧ របនាសម្ព័ន្ធនៃការស្រាវជ្រាវ......៣

## ជំពូកទី២
## ការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធ

២.១ លក្ខណៈទូទៅនៃការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធ......៤
២.១.១ និយមន័យពន្ធ......៤
២.១.២ ប្រវត្តិពន្ធ......៤
២.១.៣ ទ្រឹស្ដីអំពីពន្ធ......៥
២.២ នីតិវិធីនៃការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធ ......៥
២.២.១ និយមន័យអ្នកជាប់ពន្ធ......៥
២.២.២ ទ្រឹស្ដីអ្នកជាប់ពន្ធ......៦
២.២.៣ លក្ខខណ្ឌអ្នកជាប់ពន្ធ ......៦
២.៣ សារៈសំខាន់នៃការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធ......៦

២.៣.១ និយមន័យការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធ ........ ៦
២.៣.២ ទ្រឹស្តីនៃការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធ ........ ៧
២.៣.៣ សារៈសំខាន់នៃការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធ ........ ៧

## ជំពូកទី៣

## ការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធ សាខាទួលគោក

៣.១ ស្ថានភាពទូទៅនៃការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធ សាខាទួលគោក ........ ៨
៣.១.១ ប្រវត្តិរបស់ពន្ធដារសាខាទួលគោក ........ ៨
៣.១.២ ចក្ខុវិស័យ បេសកកម្ម គោលដៅ របស់ពន្ធដារសាខាទួលគោក ........ ៩
ក.ចក្ខុវិស័យ ........ ៩
ខ.បេសកកម្ម ........ ៩
គ.គោលដៅ ........ ៩
៣.១.៣ រចនាសម្ព័ន្ធគ្រប់គ្រង តួនាទី នឹងភារកិច្ច របស់ពន្ធដាសាខាទួលគោក ........ ១០
ក. រចនាសម្ព័ន្ធគ្រប់គ្រង ........ ១០
ខ. តួនាទីគណគ្រប់គ្រង ........ ១១
គ. ភារកិច្ចគណគ្រប់គ្រង ........ ១២
៣.២ នីតិវិធីនៃការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធ ........ ១៤
៣.២.១ កាតព្វកិច្ចនៃការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធ ........ ១៤
៣.២.២ នីតិវិធីការធ្វើបច្ចុប្បន្នភាពព័ត៌មានរបស់អ្នកជាប់ពន្ធ ........ ១៤
៣.២.៣ កម្រៃសេវា ការបង់ពន្ធប៉ាតង់និងពន្ធប្រថាប់ត្រាលើឯកសារ ........ ៤០
៣.២.៤ រយៈពេល ទទួលបានការចុះបញ្ជី និងការធ្វើបច្ចុប្បន្នភាព ........ ៤២
៣.៣ អត្ថប្រយោជន៍នៃការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធ ........ ៤២
៣.៣.១ ការចុះពិនិត្យស្ថានភាពអាជីវកម្ម ........ ៤២
៣.៣.២ ការបដិសេធការស្នើសុំចុះបញ្ជីពន្ធដារ និងបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ ........ ៤២
៣.៣.៣ ការចុះបញ្ជីឯកតោភាគី និងបញ្ជីអវិជ្ជមានសម្រាប់ការចុះបញ្ជី ........ ៤៣
៣.៣.៤ អត្ថប្រយោជន៍នៃការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធ ........ ៤៤

## ជំពូកទី៤

## ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

៤.១ ការវិភាគលើចំណុចខ្លាំង ........ ៤៦
៤.២ ការវិភាគលើចំណុចខ្សោយ ........ ៤៦

## ជំពូកទី៥
## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

៥.១ សេចក្តីសន្និដ្ឋាន ........................................................ ៤៧
៥.២ ការផ្តល់អនុសាសន៍ ........................................................ ៤៧

# ជំពូកទី១
# សេចក្តីផ្តើម

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

នៅគ្រប់ប្រទេសនៅក្នុងសកលលោកយើងនេះ ការប្រមូលពន្ធ គឺជាប្រភពចំណូលយ៉ាងសំខាន់មួយ ដែលនៅក្នុងចំណោមប្រភពចំណូលផ្សេងៗទៀត វាដើរតួយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍ប្រទេសឱ្យមានការរីកចម្រើន។ ហេតុដូចនេះហើយ ទើបនៅបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ចំណូលក្នុងស្រុកត្រូវបានទទួលស្គាល់ ថាជាប្រភពធនធានមួយដ៏មានសារៈសំខាន់ សម្រាប់ធានាចីរភាពនៃការអភិវឌ្ឍន៍ ខណៈដែលជំនួយហិរញ្ញប្បទានពីខាងក្រៅត្រូវបានរំពឹងថា នឹងមានទំហំមិនគ្រប់គ្រាន់ឱ្យឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍន៍ឥតឈប់ឈរនៃសង្គមទៅតាមភូមិសាស្ត្រ ទីកន្លែងនានា និងតម្រូវការជាក់ស្តែង។ ដោយមើលឃើញមូលហេតុនេះហើយ ទើបបណ្តាប្រទេសនានា បានចាប់ផ្តើមបង្កើននូវការប្រមូលពន្ធ ក៏ដូចជាដាក់ចេញនៅលិខិតបទដ្ឋានគតិយុត្ត ឬបទប្បញ្ញត្តិនានា ដើម្បីធានានៅសុវត្ថិភាព និងប្រសិទ្ធភាពលើការប្រមូលពន្ធ។

ជាក់ស្តែង សូម្បីតែប្រទេសកម្ពុជាយើង ដែលជាប្រទេសដែលធ្លាប់ឆ្លងកាត់សង្គ្រាម ក៏ទទួលបានការជួយជ្រោមជ្រែងពីការប្រមូលពន្ធ ហើយធ្វើឱ្យប្រទេសមានការរីកចម្រើន និងមានសក្តានុភាពក្នុងការសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ច និងជួយក្នុងការកាត់បន្ថយភាពក្រីក្រ ដែលជាសមិទ្ធផលគួរជាទីមោទនៈមួយក្នុងចំណោមបណ្តាប្រទេស ដែលមានការអភិវឌ្ឍន៍ទាបនានាលើសកលលោក។ ការរីកចម្រើននេះ ក៏មិនអាចកាត់ផ្តាច់ចេញពីវិស័យសេដ្ឋកិច្ចសង្គម និងប្រជាសាស្ត្រឡើយ។

ដើម្បីបន្តធានាឱ្យបាននូវចីរភាព និងវឌ្ឍនភាពក្នុងទិសដៅប្រែក្លាយកម្ពុជា ឱ្យទៅជាប្រទេសមួយដែលមានចំណូលមធ្យមកម្រិតខ្ពស់នាពេលខាងមុខ នៅក្នុងដំណាក់កាលផ្លាស់ប្តូរនេះផងដែរ រាជរដ្ឋាភិបាលមានតម្រូវការចាំបាច់ ក្នុងការកសាងប្រព័ន្ធចំណូលថវិកាជាតិឱ្យរឹងមាំប្រកបដោយប្រសិទ្ធភាព និងតម្លាភាព ដើម្បីកសាងប្រភពចំណូលឱ្យបានច្បាស់លាស់ និងមានស្ថេរភាព ក្នុងការឆ្លើយតបទៅនឹងសេចក្តីចំណាយសម្រាប់ការអភិវឌ្ឍន៍ដូចជា ការកសាង និងកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការពង្រឹងវិស័យអប់រំ ការបណ្តុះបណ្តាលជំនាញដល់យុវជន និងយុវនារី ការធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវាសុខាភិបាល ការរៀបចំ និងដាក់ឱ្យប្រើប្រាស់នូវសំណាញ់សុវត្ថិភាពសង្គម និងការពង្រឹងគុណភាពនៃការផ្តល់សេវាសាធារណៈ។ល។

ដូច្នេះ កត្តាទាំងនេះទាមទារឱ្យកម្ពុជាខិតខំប្រឹងប្រែងដោយខ្លួនឯងក្នុង ការកៀរគរចំណូលទាំងរយៈពេលខ្លី និងមធ្យមឱ្យបានច្រើនថែមទៀត ដើម្បីឆ្លើយតបនឹងសេចក្តីត្រូវការដូចពោលខាងលើ។ ដោយមើលឃើញពីចំណុចសំខាន់ៗដែលបានរៀបរាប់ខាងលើនេះហើយ ទើបក្រុមយើងខ្ញុំសម្រេចចិត្តជ្រើសរើសប្រធានបទមួយស្តីពី “ **ការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធ** ” យកមកធ្វើការស្រាវជ្រាវ ជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ការប្រមូលពន្ធ ពិតជាមានសារៈសំខាន់ណាស់ ក្នុងការជួយឱ្យប្រទេសជាតិមានការរីកចម្រើន ហើយធ្វើឱ្យប្រទេសមានការអភិវឌ្ឍន៍។ ហេតុដូចនេះ ទើបក្រុមយើងខ្ញុំ បានលើកយកនូវសំណួរមួយចំនួនមកចោទសួរដូចខាងក្រោម៖

១. តើដើម្បីធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធត្រូវបំពេញឯកសារអ្វីខ្លះ ?

២. តើការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធមានអត្ថប្រយោជន៍សំខាន់អ្វីខ្លះ?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការស្រាវជ្រាវនេះ គឺបង្ហាញពីការដាក់ចេញនូវបទប្បញ្ញត្តិ និងការធ្វើបច្ចុប្បន្នភាពអ្នកជាប់ពន្ធដោយផ្តោតទៅលើ ៖

- ប្រៀបធៀបទ្រឹស្តី ជាមួយនឹងការអនុវត្តជាក់ស្តែង
- សិក្សាទៅលើស្ថានភាពទូទៅរបស់អង្គភាព
- ស្រាវជ្រាវពីចំណុចខ្លាំង និងចំណុចខ្សោយអង្គភាព
- គោលនយោបាយ បេសកកម្ម និងទស្សនវិស័យ
- តួនាទី និងភារកិច្ចពន្ធដារ
- លក្ខណសម្បត្តិនៃការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធ។

## ១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៤.១ ទំហំដែនកំណត់

ការសិក្សាស្រាវជ្រាវនេះ គឺសិក្សាទៅលើការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធ សាខាពន្ធដារ ខណ្ឌទួលគោក ដែលមានទីតាំងស្ថិតនៅ ផ្ទះលេខ២៤ ផ្លូវលេខ២៨៧ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។ យើងផ្តោតសំខាន់ទៅលើការដាក់ចេញនូវបទប្បញ្ញត្តិ នីតិវិធីនៃការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធរបស់ពន្ធដារ។

### ១.៤.២ វិសាលភាពនៃការស្រាវជ្រាវ

ដំណើរការនៃការស្រាវជ្រាវនេះ ធ្វើឡើងដើម្បីឆ្លុះបញ្ចាំងពីតថភាពនៃការដាក់ចេញនូវបទប្បញ្ញត្តិ នីតិវិធី នៅក្នុងនាយកដ្ឋានពន្ធដារ សម្រាប់ឆ្នាំ២០២៣តែប៉ុណ្ណោះ។

## ១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

### ១.៥.១ ការប្រមូលទិន្នន័យបន្ទាប់

ការប្រមូលទិន្នន័យបន្ទាប់ គឺជាការប្រមូលទិន្នន័យតាមរយៈការស្រាវជ្រាវក្នុងបណ្ណាល័យ សារណាសិស្សច្បង និងតាមរយៈគេហទំព័ររបស់នាយកដ្ឋានពន្ធដារ។

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះមានសារៈសំខាន់ និងគុណប្រយោជន៍ដូចជា ៖

- បង្ហាញពីចំណុចខ្លាំងចំណុចខ្សោយរបស់នាយកដ្ឋានដើម្បីធ្វើការកែលម្អរ
- បង្កើនការយល់ដឹងទៅលើការប្រមូល និងកែប្រែនីតិវិធីក្នុងការប្រមូលពន្ធ
- បង្កើនការយល់ដឹងផ្ទាល់ខ្លួនដោយផ្សារភ្ជាប់រវាងទ្រឹស្តីនឹងការអនុវត្ត
- យល់ដឹងពីការដាក់ចេញនូវបទប្បញ្ញត្តិរបស់រាជរដ្ឋាភិបាលនិងពន្ធដារ
- ចងក្រងទុកជាឯកសារផ្តល់យោបល់នឹងបទពិសោធន៍ខ្លះៗដល់អ្នកសិក្សាជំនាន់ក្រោយ
- បង្កើនចំណេះដឹងទៅលើការសិក្សាស្រាវជ្រាវក៏ដូចជាការធ្វើស្វ័យសិក្សា។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ចំពោះការស្រាវជ្រាវនេះត្រូវបានបែងចែកជា៥ជំពូកដូចខាងក្រោម ៖

**ជំពូកទី១៖** សេចក្តីផ្តើមនិយាយពី លំនាំចំណោទបញ្ហាគោលបំណងវិសាលភាពដែនកំណត់ និងវិធីសាស្រ្តព្រមទាំងរចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ។

**ជំពូកទី២៖** រំលឹកទ្រឹស្តីនិយាយពី ទ្រឹស្តីដែលពាក់ព័ន្ធទស្សនៈទាន ឬសម្តីរបស់អ្នកប្រាជ្ញ និងបទពិសោធន៍ ហើយនិយាយពីលក្ខណៈទូទៅនៃការចុះបញ្ជី និងការធ្វើបច្ចុប្បន្នភាពអ្នកជាប់ពន្ធ ។

**ជំពូកទី៣៖** លទ្ធផលនៃការស្រាវជ្រាវនិយាយអំពី ស្ថានភាពទូទៅ ប្រវត្តិអត្តសញ្ញាណ និងនីតិវិធីសារៈសំខាន់នៃការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធ។

**ជំពូកទី៤៖** ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ នៃការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធ។

**ជំពូកទី៥៖** សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍ គឺធ្វើសេចក្តីសន្និដ្ឋានទៅលើធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធ ហើយបញ្ចេញនូវមតិយោបល់ផ្តល់អនុសាសន៍ផ្ទាល់ខ្លួនមួយចំនួនដែលពាក់ព័ន្ធទៅនឹងការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធទៅតាមចំណេះដឹងដែលខ្លួនបានសិក្សាមក។

# ជំពូកទី២
# រំលឹកទ្រឹស្តី

# ជំពូកទី២
# ការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធ

## ២.១ លក្ខណៈទូទៅនៃការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធ

### ២.១.១ និយមន័យពន្ធ

**ពន្ធ** គឺជារូបភាពនៃការបែងចែកឡើងវិញ នូវចំណូលជាតិដែលរដ្ឋាភិបាលបានប្រើប្រាស់ដើម្បីប្រមូលចំណូលមួយផ្នែកពីគ្រប់សមាសភាពសេដ្ឋកិច្ចដូចជា ក្រុមហ៊ុនសហគ្រាស អាជីវកម្ម សិប្បកម្ម ពាណិជ្ជកម្ម និងប្រជាពលរដ្ឋដើម្បីបម្រើឱ្យតម្រូវការរួមរបស់សង្គមជាតិទាំងមូល។

**ពន្ធ** គឺជារូបធាតុនៃការប្រមូលចំណូលមួយដែលផ្សារភ្ជាប់ជាមួយនិងសិទ្ធអំណាចនយោបាយរដ្ឋាភិបាលដែលក្រិត្យច្បាប់ជាកំណត់។

**ពន្ធ** គឺជាការបង់វិភាគទាននូវកាតព្វកិច្ច របស់គ្រប់សមាសភាពសេដ្ឋកិច្ចដែលរួមទាំង រូបវន្តបុគ្គល នីតិបុគ្គល ជូនរដ្ឋាភិបាលដែលមានច្បាប់កំណត់។

**ពន្ធ** គឺសំដៅទៅលើអាករ (ទាំងពន្ធប្រយោល និងពន្ធផ្ទាល់)។

**ពន្ធ** គឺជាវិភាគទានលក្ខណៈភាតព្វកិច្ច (ចាប់បង្ខំ)ស្របតាមច្បាប់កំណត់ ដែលអ្នកជាប់ពន្ធទាំងរូបវន្តបុគ្គល និង នីតិបុគ្គលត្រូវបង់ជូនរដ្ឋ។ ការយកពន្ធ ជាមធ្យោបាយជាក់ស្តែងមួយដែលរដ្ឋប្រើប្រាស់សម្រាប់បង្កើនប្រាក់ចំណូល និងបំពេញតម្រូវការចំណាយរបស់រដ្ឋ។

**ពន្ធ** គឺជាបន្ទុករបស់រដ្ឋបង់ចូលថវិកាជាតិ ប្រជាពលរដ្ឋគ្រប់រូបមានកាតព្វកិច្ចបង់ពន្ធ ហើយទទួលតម្លៃតបស្នងពីរដ្ឋាភិបាលតាមរយៈទំនិញឬ សេវាសាធារណៈ។

**ពន្ធ** ជាការបង្ខិតបង្ខំ ឬជាការចាំបាច់ដោយខានពុំបានដែលរដ្ឋត្រូវតែដក ឬប្រមូលផ្អែកលើមូលដ្ឋានដែលកំណត់ដោយច្បាប់ និងមានទិសដៅបំពេញរាល់ការប្រើប្រាស់របស់រដ្ឋ។

**ពន្ធ** គឺជាបន្ទុករបស់អ្នកជាប់ពន្ធចំពោះរដ្ឋ ដែលជាកាតព្វកិច្ចរបស់គ្រប់សមាសភាពដែលកំណត់ដោយច្បាប់។

### ២.១.២ ប្រវត្តិរបស់ពន្ធ

ពន្ធដំបូង ត្រូវបានកំណត់ចំពោះប្រទេសអេស៊្សីប។ នៅសម័យដើមនៃសាធារណរដ្ឋរ៉ូម៉ាំងសាធារណៈមានការវាយតម្លៃតិចតួចលើទ្រព្យសម្បត្តិ និងទ្រព្យដែលជាកម្មសិទ្ធិ។ អត្រាពន្ធធម្មតាពី១% ហើយពេលខ្លះអាចឡើងដល់៣% ក្នុងស្ថានភាពដូចជាសង្គ្រាម។ ពន្ធតិចតួចទាំងនេះ ត្រូវបានគេយកទៅលើដីធ្លីផ្ទះ និងអចលនទ្រព្យផ្សេងទៀតមានដូចជា ទាសករ សត្វ របស់របរផ្ទាល់ខ្លួន និងទ្រព្យសម្បត្តិរូបិយវត្ថុ។ មនុស្សមានទ្រព្យកាន់តែច្រើនពន្ធកាន់តែច្រើន។ ពន្ធត្រូវបានប្រមូលពីបុគ្គលម្នាក់ៗ ។

ចំពោះប្រទេសកម្ពុជា រដ្ឋធម្មនុញ្ញថ្មីត្រូវបានអនុម័តនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣។ ព្រះបាទនរោត្តមសីហនុ ត្រូវបានឡើងសោយរាជ្យបន្តដែលការតែងតាំងដំបូងបង្អស់លើព្រះអង្គក្នុងឆ្នាំ១៩៤១។

ប្រព័ន្ធពន្ធដារត្រូវបានបង្កើតនៅឆ្នាំ១៩៥៣ បន្ទាប់មកត្រូវលុបបំបាត់ចោលនៅឆ្នាំ១៩៧៥-១៩៧៩ ដោយសារសង្គ្រាម (របបប៉ុលពត)។ ប្រព័ន្ធពន្ធដារត្រូវបានបង្កើតឡើងដំណាក់កាលដំបូងឆ្នាំ១៩៨០ ដែលបានអនុវត្តនៅរាជធានីភ្នំពេញ និងខេត្តចំនួន១០ផ្សេងទៀត។ លើសពីនេះទៅទៀត អគ្គនាយកដ្ឋានពន្ធដារបានបង្កើតពន្ធមួយចំនួនផ្សេងទៀត ដើម្បីអនុវត្តនឹងមានការចែងច្បាប់ព្រមទាំងមាត្រាយ៉ាងច្បាស់លាស់។

ផ្អែកលើមាត្រាទី៤ នៃច្បាប់សារពើពន្ធបានបង្កើតនៅរបបកំណត់ពន្ធដារ៣ប្រភេទ៖ របបពិត របបម៉ៅការ និង របបបំពេញដែលមានចែងជាច់ដោយឡែក។ ប៉ុន្តែនៅពេលបច្ចុប្បន្ននេះប្រទេសកម្ពុជាយើងមានតែរបបពិត។

**២.១.៣ ទ្រឹស្តីអំពីពន្ធ**

ពន្ធ មានលក្ខណៈបង្ខំហើយមិនសងឱ្យវិញផ្ទាល់ឡើយ ប៉ុន្តែនឹងអាចសងមកវិញជាលក្ខណៈរូបភាពប្រយោលទៅតាមគោលនយោបាយរដ្ឋាភិបាលប្រទេសនីមួយៗ។ គ្រប់អង្គភាពអាជីវកម្ម ផលិតកម្ម សេវាកម្ម ចំណុះឱ្យគ្រប់សមាសភាពសេដ្ឋកិច្ចត្រូវមានកាតព្វកិច្ច និងទំនួលខុសត្រូវចំពោះមុខច្បាប់រដ្ឋ ក្នុងការអនុវត្តឱ្យបានគ្រប់គ្រាន់ក្នុងខ្ទង់ពន្ធទាំងឡាយ ដែលបានកំណត់ និងមានសិទ្ធស្មើៗគ្នាក្នុងការទទួលមកវិញ នូវផលប្រយោជន៍ពីរដ្ឋាភិបាល ដែលប្រកបដោយយុត្តិធម៌ និងត្រូវបានរដ្ឋាភិបាលបង្កលក្ខណៈងាយស្រួលមកវិញតាមរយៈគោលនយោបាយដែលមានបែងចែកក្នុងច្បាប់។

ពន្ធ បានធ្វើឱ្យមានការផ្លាស់ប្តូរកម្មសិទ្ធ នៃប្រភពចំណូលដែលបានប្រមូល។ បន្លាស់ប្តូរកម្មសិទ្ធិនៃប្រភពចំណូលនេះបានកំណត់ដោយមុខងារគ្រប់គ្រងសេដ្ឋកិច្ចរបស់រដ្ឋាភិបាល ហើយបានស្តែងឡើងការឯកភាពគ្នា អំពីគោលចរឹតផលប្រយោជន៍របស់រដ្ឋជាមួយ និងផលប្រយោជន៍របស់ក្រុមហ៊ុនអាជីវកម្ម សេវាកម្ម និងប្រជាជនគ្រប់រូប។ នៅក្នុងយឿនសេដ្ឋកិច្ច ទីផ្សារដែលមានសមាសភាពសេដ្ឋកិច្ចច្រើន គោលនយោបាយពន្ធដារត្រូវយកមកប្រើប្រាស់ជាចាំបាច់ ជាទូទៅពន្ធត្រូវបានចាត់ទុកជាឧបករណ៍ហិរញ្ញវត្ថុមួយយ៉ាងមានប្រសិទ្ធភាពក្នុងការគ្រប់គ្រងសេដ្ឋកិច្ច។

## ២.២ ឯកសារធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធ

**២.២.១ និយមន័យអ្នកជាប់ពន្ធ**

**អ្នកជាប់ពន្ធ** គឺសំដៅដល់អ្នកជាប់ពន្ធទាំងឡាយ ដែលមានកាតព្វកិច្ចត្រូវបង់ពន្ធទាំងនិវាសនជន និង អនិវាសនជន ។

អ្នកជាប់ពន្ធនិវាសនជន សំដៅដល់ ៖

- រូបវន្តបុគ្គលដែលមាននិវាសនដ្ឋាន ឬមានកន្លែងស្នាក់នៅជាគោលដើម នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬដែលមានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជាលើសពី១៨២ (មួយរយប៉ែតសិបពីរ) ថ្ងៃនៅក្នុងរយៈពេល១២(ដប់ពីរ)ខែណាមួយដែលបានបញ្ចប់ក្នុងឆ្នាំជាប់ពន្ធចរន្ត។
- នីតិបុគ្គលឬក្រុមហ៊ុនសហកម្មសិទ្ធិ ដែលត្រូវបានបង្កើតឬត្រូវបានគ្រប់គ្រងនៅក្នុង ព្រះរាជាណាចក្រកម្ពុជា ឬដែលមានកន្លែងប្រកបអាជីវកម្មជាគោលដើម នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

អ្នកជាប់ពន្ធអនិវាសនជន សំដៅដល់បុគ្គលណាមួយ ដែលមិនមែនជាអ្នកជាប់ពន្ធនិវាសនជនតាមកថាខណ្ឌទី១នៃមាត្រានេះ និងទទួលប្រាក់ចំណូលប្រភពកម្ពុជា។

**២.២.៣ ទ្រឹស្តីអ្នកជាប់ពន្ធ**

នៅក្នុងបទប្បញ្ញត្តិ ស្តីពីពន្ធដារនៃព្រះរាជាណាចក្រកម្ពុជាមានចែងថា អ្នកជាប់ពន្ធ គឺជាបុគ្គលទាំងឡាយណា ដែលមានកាតព្វកិច្ចបង់ពន្ធ។

អ្នកជាប់ពន្ធគឺជារូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណាដែលបានកត់ត្រាចូលក្នុងបញ្ជីផលិតកម្ម អាជីវកម្ម សេវាកម្ម... របស់រដ្ឋាភិបាល ហើយរាល់សកម្មភាពផ្សេងៗ ត្រូវបានរដ្ឋទទួលស្គាល់ជាសាធារណៈ និងបានកំណត់កាតព្វកិច្ច កំណត់កាតព្វកិច្ចបង់ពន្ធជូនរដ្ឋាភិបាលទៅតាមការកំណត់របស់អង្គការពន្ធ។

**២.២.២ លក្ខខណ្ឌអ្នកជាប់ពន្ធ**

អ្នកជាប់ពន្ធ ត្រូវបានកំណត់តាម២ករណីដោយឡែកពីគ្នា ចំពោះសហគ្រាសដែលប្រកបអាជីវកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា គឺ ៖

**ក.ការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស**

ការកំណត់ចំណាត់ថ្នាក់ អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសត្រូវផ្អែកលើកម្រិតផលរបរប្រចាំឆ្នាំទៅតាមវិស័យចម្បងរួមមាន វិស័យកសិកម្ម ឧស្សាហកម្ម សេវាកម្ម និងពាណិជ្ជកម្ម។

**ខ. ការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមទ្រព្យសកម្មអាជីវកម្ម**

ក្នុងករណីផលរបរដែលអ្នកជាប់ពន្ធ បានប្រកាសមិនឆ្លុះបញ្ចាំងនូវផលរបរជាក់ស្តែង នោះការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធត្រូវបានធ្វើឡើងវិញ ដោយផ្អែកលើតម្លៃទ្រព្យសកម្មដែលប្រើប្រាស់ក្នុងអាជីវកម្ម។

## ២.៣. សារៈសំខាន់នៃការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធ

**២.៣.១ និយមន័យការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធ**

ការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធ គឺសំដៅលើអ្នកជាប់ពន្ធដែលបានចុះបញ្ជីពន្ធដារ មានកាតព្វកិច្ចជូនដំណឹងមករដ្ឋបាលសារពើពន្ធ ក្នុងអំឡុងពេល១៥ថ្ងៃ នៃថ្ងៃធ្វើការក្នុងករណីដែលមានការប្រែប្រួល ព័ត៌មានណាមួយនៃអាជីវកម្មរបស់ខ្លួន។

ការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធ សំដៅលើអ្នកជាប់ពន្ធដែលមានការផ្លាស់ប្តូរព័ត៌មានណាមួយដូចមានចែង តម្រូវឱ្យមកធ្វើបច្ចុប្បន្នភាពព័ត៌មានដោយត្រូវបំពេញព័ត៌មាន និងភ្ជាប់មកនូវឯកសារចុងក្រោយនៃឯកសារបញ្ជាក់ការផ្លាស់ប្តូរព័ត៌មាននោះតែប៉ុណ្ណោះ ដូចមានកំណត់ក្នុងពាក្យស្នើសុំចុះបញ្ជីពន្ធដារ និងបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ(ទម្រង់១០១) ចំណែកការផ្លាស់ប្តូរព័ត៌មានសាខា ឬបន្ថែមសាខា អ្នកជាប់ពន្ធត្រូវបំពេញព័ត៌មានសាខាតាមទម្រង់ 909-C និងភ្ជាប់ឯកសារដូចមានកំណត់ក្នុងឧបសម្ព័ន្ធ ស្តីពីឯកសារតម្រូវសម្រាប់បច្ចុប្បន្នភាពព័ត៌មាន។

**២.៣.២ ទ្រឹស្តីការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធ**

ការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធ សំដៅដល់អ្នកជាប់ពន្ធដែលបានចុះបញ្ជីពន្ធដារ ប៉ុន្តែនៅមិនទាន់មានលេខអត្តសញ្ញាណកម្មសារពើពន្ធ តាមទម្រង់ថ្មីដែល រដ្ឋបាលសារពើពន្ធបានកំណត់។

ការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធ សំដៅដល់នៅពេលដែលរដ្ឋបាលសារពើពន្ធពិនិត្យឃើញថា អ្នកជាប់ពន្ធបានប្រើប្រាស់ព័ត៌មានមិនពិត ឬមិនត្រឹមត្រូវ ឬមិនគ្រប់គ្រាន់ ឬមិនច្បាស់លាស់ ឬឯកសារក្លែងក្លាយ រដ្ឋបាលសារពើពន្ធអាចអញ្ជើញអ្នកជាប់ពន្ធ ដែលបានចុះបញ្ជីពន្ធដារ តាមគេហទំព័រចុះបញ្ជីអាជីវកម្មមកផ្តល់ព័ត៌មានបន្ថែម ឬមកធ្វើបច្ចុប្បន្នភាព។

**២.២.៣ សារៈសំខាន់នៃការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់**

គោលបំណងនៃការធ្វើបច្ចុប្បន្នភាបរបស់អ្នកជាប់ពន្ធ ៖

- ពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការចុះបញ្ជីពន្ធដារ ដើម្បីគ្រប់គ្រងឱ្យបានកាន់តែប្រសើរឡើងនូវទិន្នន័យរបស់អ្នកជាប់ពន្ធ
- គាំទ្រដល់ការផ្តល់សេវាដល់អ្នកជាប់ពន្ធឱ្យបានកាន់តែល្អប្រសើរ
- ទទួលបានការគាំពារតាមផ្លូវច្បាប់ ជៀសវាងការប្រឈម នឹងការផាកពិន័យផ្សេងៗ
- ជួយពង្រឹកក្នុងការប្រមូលពន្ធចូលរដ្ឋ
- ជួយជំរុញឱ្យមាការកើនឡើងនៅចំណូលជាតិ
- ទទួលព័ត៌មាន អំពីសិទ្ធិរបស់ខ្លួន រួមទាំងសិទ្ធិក្នុងការប្តឹងតវ៉ា
- ទទួលបានការអនុវត្តដោយមានតម្លាភាព និងមិនលម្អៀងពីសំណាក់រដ្ឋបាល សារពើពន្ធ
- ទទួលបានការទទួលស្គាល់ អំពីភាពស្មោះត្រង់ ក្នុងការអនុវត្តកាតព្វកិច្ចសារពើពន្ធ
- គាំទ្រដល់ការគ្រប់គ្រង ការដាក់លិខិតប្រកាស ការធ្វើសវនកម្ម និងការប្រមូលបំណុលពន្ធឱ្យកាន់តែមានតម្លាភាព និងប្រសិទ្ធភាព។
- គោលបំណងពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការចុះបញ្ជីពន្ធដារ និងការគ្រប់គ្រងទិន្នន័យរបស់អ្នកជាប់ពន្ធ ដើម្បីគាំទ្រដល់ការផ្តល់សេវាដល់អ្នកជាប់ពន្ធ និងការគ្រប់គ្រង ប្រមូលពន្ធឱ្យកាន់តែមានគម្លាភាព និងប្រសិទ្ធភាព។

# ជំពូកទី៣
# លទ្ធផលស្រាវជ្រាវ

# ជំពូកទី៣

# ការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធ សាខាទួលគោក

## ៣.១ ស្ថានភាពទូទៅនៃការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធសាខាទួលគោក

### ៣.១.១ ប្រវត្តិពន្ធដារ

នៅឆ្នាំ១៨៦៣ បារាំងបានចូលមកធ្វើជាអាណាព្យាបាលខ្មែរ ហើយក្រោយមកបានប្រែក្លាយកម្ពុជាទៅជាប្រទេស ដែលនៅក្រោមអាណានិគមរបស់ខ្លួននៅឆ្នាំ១៨៨៤ បារាំងបាននាំយកច្បាប់ និងការគ្រប់គ្រងរដ្ឋបាលមកអនុវត្តន៍នៅប្រទេសកម្ពុជា ជាពិសេសវិស័យសារពើពន្ធ។ ក្រោយពេលទទួលបានឯករាជ្យពីបារាំងនៅថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ កម្ពុជាមានភាពវិបាកក្នុងការវិលត្រឡប់ទៅរកការអនុវត្តន៍ ច្បាប់ខ្មែរបុរាណវិញពោលគឺ កម្ពុជាបានក្លាយជាប្រទេស នៃគ្រួសារប្រព័ន្ធរមាំង អាឡឺម៉ង់រួចទៅហើយ។ ច្បាប់ពន្ធដារកម្ពុជា គឺជាច្បាប់ពន្ធដារដែលមាន ឫសល់ចេញមកពីច្បាប់បារាំង។ បច្ចុប្បន្ននេះ កម្ពុជាមានច្បាប់ពន្ធដារបែបទំនើប និងរីកចម្រើនល្មមជាអាទិ៍ ច្បាប់ស្តីសារពើពន្ធត្រូវបានបង្កើតឡើងនាឆ្នាំ១៩៩៧ និងបទបញ្ញត្តិផ្សេងៗទៀត និងបានរៀបចំឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ការរៀបចំបែបនេះ ធ្វើឡើងដើម្បីឆ្លើយតបទៅនឹងមាត្រា៥៧ នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ដែលចែងថា ការយកពន្ធដារ និងអាចធ្វើទៅបានលុះត្រាតែមានច្បាប់អនុញ្ញាត។ ជាការពិតណាស់យើងសង្កេតឃើញថា រដ្ឋបានកសាងច្បាប់ និងលិខិតបទដ្ឋានជាច្រើន ដើម្បីធ្វើឱ្យការប្រមូលពន្ធពីពលរដ្ឋមានលក្ខណៈនីត្យានុកូល។ អង្គភាពពន្ធដារមានប្រវត្តិ៖

- ១៩៥៣ ត្រូវបានបង្កើតឡើងជានាយកដ្ឋានពន្ធដារ
- ១៩៧៥ ដល់ ១៩៧៩ ពន្ធដារត្រូវលុបបំបាត់ចោលដោយរបបប៉ុលពត
- ១៩៨០ នាយកដ្ឋានពន្ធដារត្រូវបានបង្កើតឡើងវិញ
- ២០០៨ នាយកដ្ឋានពន្ធដារ បានដំឡើងទៅជា អគ្គនាយកដ្ឋានពន្ធដារដោយសាលាជាតិពន្ធដារ។



### ៣.១.២ ចក្ខុវិស័យ បេសកកម្ម គោលដៅ របស់ពន្ធដារ សាខាខ្ទួលគោក

**ក. ទស្សនវិស័យ**

អគ្គនាយកដ្ឋានពន្ធដារ ជាអង្គភាពសាធារណៈដែលត្រូវបានជឿជាក់គោរព និងទទួលស្គាល់លើគុណភាព និងជំនាញក្នុងការប្រមូលចំណូលពន្ធដារ ដើម្បីជំរុញកំណើនសេដ្ឋកិច្ច និងកាអភិវឌ្ឍប្រកបដោយចីរភាព។

**ខ.បេសកកម្ម**

អគ្គនាយកដ្ឋានពន្ធដារ ផ្តល់នូវសេវាដែលមានគុណភាព និងពង្រឹងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារប្រកបដោយភាពសុចរិត និងស្មើភាពចំពោះអ្នកជាប់ពន្ធទាំងអស់ ដើម្បីជួយជំរុញអនុលោមភាពដោយស្ម័គ្រចិត្តឈានទៅសម្រេចបាននូវការអភិវឌ្ឍ និងលើកកម្ពស់សុខុមាលភាពរបស់ប្រជាជនកម្ពុជា។

**គ. គុណតម្លៃ**

អគ្គនាយកដ្ឋានពន្ធដារ បំពេញបេសកកម្ម និងធ្វើប្រតិបត្តិការរបស់ខ្លួនដោយប្រកាន់ខ្ជាប់នូវគុណតម្លៃដូចខាងក្រោម៖

- ការអនុវត្ត ៖ អនុវត្តវិធាននៃច្បាប់គាំទ្រប្រជាពលរដ្ឋ ដែលប្រព្រឹត្តត្រឹមត្រូវតាមច្បាប់ និងតឹងរ៉ឹងចំពោះជនដែលមិនអនុលោមតាមច្បាប់
- វិជ្ជាជីវៈ ៖ ប្តេជ្ញាចិត្តប្រើវិជ្ជាជីវៈ និងជំនាញដើម្បីផ្តល់នូវសេវាដែលមាន ភាពសាមញ្ញ និងងាយស្រួល
- ស័ក្តិសិទ្ធិភាព ៖ ប្រើប្រាស់ធនធានឱ្យទាន់ ពេលវេលា និងមានប្រសិទ្ធភាព
- សុចរិតភាព ៖ ផ្តល់សេវាឱ្យប្រជាពលរដ្ឋដោយស្មើភាព និងតម្លាភាព
- គារវភាព ៖ ផ្តល់សេវាឱ្យប្រជាពលរដ្ឋ ប្រកបដោយភាពថ្លៃថ្នូរ និងការគោរព
- ភាពបត់បែន ៖ ឆ្លើយតបយ៉ាងសកម្មទៅនឹងបញ្ហាប្រឈម និងទាញយកប្រយោជន៍ពីគ្រប់ឱកាសដែលមាន។

## ៣.១.៣ រចនាសម្ព័ន្ធគ្រប់គ្រង តួនាទី និងភារកិច្ច របស់ពន្ធដារ សាខាទួលគោក

### ក. រចនាសម្ព័ន្ធគ្រប់គ្រង




**យោង៖**

- ប្រកាសលេខ ១២៣២ សហវ.ប្រក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃអគ្គនាយកដ្ឋានពន្ធដារ។
- ប្រកាសលេខ ២១២ សហវ.ប្រក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាននៃអគ្គនាយកដ្ឋានពន្ធដារ។
- ប្រកាសលេខ ៤៩៣ សហវ.អពដ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០ ស្តីពីការកែសម្រួលប្រកាសលេខ ១២៣២ សហវ.ប្រក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គនាយកដ្ឋានពន្ធដារ ដើម្បីបំពេញបន្ថែមភារកិច្ច និងរចនាសម្ព័ន្ធឱ្យនាយកដ្ឋានពន្ធចលនទ្រព្យនិងអចលនទ្រព្យ និងសាខាពន្ធដារខេត្ត។
- ប្រកាសលេខ ៩៦៦ សហវ.ប្រក ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២០ ស្តីពីការបង្កើតការិយាល័យសវនកម្មសហគ្រាសទី៩ និងទី១០ នៃនាយកដ្ឋានសវនកម្មសហគ្រាស។
- ប្រកាសលេខ ៩៦៧ សហវ.ប្រក ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២០ ស្តីពីការកែសម្រួលការិយាល័យធានាគុណភាព និងបណ្តុះបណ្តាល ទៅជាការិយាល័យធានាគុណភាព និងការិយាល័យបណ្តុះបណ្តាល នៃនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាននៃអគ្គនាយកដ្ឋានពន្ធដារ។
- ប្រកាសលេខ ៧៩០ សហវ.ប្រក ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការកែសម្រួលប្រកាសលេខ ១២៣២ សហវ.ប្រក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃអគ្គនាយកដ្ឋានពន្ធដារ ដើម្បីបំពេញបន្ថែមភារកិច្ច និងរចនាសម្ព័ន្ធ ឱ្យសាលាជាតិពន្ធដារ។
- ប្រកាសលេខ ១០២ សហវ.ប្រក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២ ស្តីពីការកែសម្រួលប្រកាសលេខ ១២៣២ សហវ.ប្រក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃអគ្គនាយកដ្ឋានពន្ធដារ ដើម្បីបំពេញបន្ថែមភារកិច្ច និងរចនាសម្ព័ន្ធឱ្យនាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ។
- ប្រកាសលេខ ១៥២ សហវ.ប្រក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការកែសម្រួលប្រកាសលេខ ១២៣២ សហវ.ប្រក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃអគ្គនាយកដ្ឋានពន្ធដារ ដើម្បីបំពេញបន្ថែមភារកិច្ច និងរចនាសម្ព័ន្ធ ឱ្យនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម។
- ប្រកាសលេខ ១៨៣ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២២ ស្តីពីការកែសម្រួលប្រកាសលេខ ១២៣២ សហវ.ប្រក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃអគ្គនាយកដ្ឋានពន្ធដារ ដើម្បីបំពេញបន្ថែមភារកិច្ច និងរចនាសម្ព័ន្ធ ឱ្យនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន។
- ប្រកាសលេខ ១៨៤ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២២ ស្តីពីការកែសម្រួលប្រកាសលេខ ១២៣២ សហវ.ប្រក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃអគ្គនាយកដ្ឋានពន្ធដារ ដើម្បីកែសម្រួលភារកិច្ចរបស់ការិយាល័យបុគ្គលិក និងបំពេញបន្ថែមរចនាសម្ព័ន្ធឱ្យនាយកដ្ឋានហិរញ្ញវត្ថុ និងបុគ្គលិក។
- ប្រកាសលេខ ១៨៥ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២២ ស្តីពីការកែសម្រួលប្រកាសលេខ ១២៣២ សហវ.ប្រក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃអគ្គនាយកដ្ឋានពន្ធដារ ដើម្បីបំពេញបន្ថែមភារកិច្ច និងរចនាសម្ព័ន្ធ ឱ្យនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ។
- ប្រកាសលេខ ២៥៥ សហវ.ប្រក ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២២ ស្តីពីការកែសម្រួលប្រកាសលេខ ១២៣២ សហវ.ប្រក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃអគ្គនាយកដ្ឋានពន្ធដារ ដើម្បីកែសម្រួលរចនាសម្ព័ន្ធឱ្យនាយកដ្ឋានពន្ធចលនទ្រព្យ និងអចលនទ្រព្យ។
- ប្រកាសលេខ ៥៣៦ សហវ.ប្រក ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២២ ស្តីពីការកែសម្រួលប្រកាសលេខ ១២៣២ សហវ.ប្រក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃអគ្គនាយកដ្ឋានពន្ធដារ ដើម្បីកែសម្រួលរចនាសម្ព័ន្ធ ឱ្យនាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ។
- ប្រកាសលេខ ១០៧០ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២២ ស្តីពីការបង្កើតការិយាល័យសវនកម្មសហគ្រាសទី១១ និងការិយាល័យជំរុញការប្រមូលបំណុលពន្ធនៃនាយកដ្ឋានសវនកម្មសហគ្រាស នៃអគ្គនាយកដ្ឋានពន្ធដារ។

**ខ. តួនាទីពន្ធដារ**

ពន្ធដារមានតួនាទីជាមូលដ្ឋានដូចខាងក្រោមៈ

១. បង្កើតប្រភពចំណូលថវិការឱ្យរដ្ឋ

ឆ្លងតាមរយៈក្រឹត្យច្បាប់នានា ច្បាប់សារពើពន្ធ ច្បាប់គ្រប់គ្រងហិរញ្ញវត្ថុ ស្តីអំពីកម្រិតកំណត់អត្រាពន្ធដែលក្រុមហ៊ុនសាជីវកម្ម សេវាកម្ម និងប្រជាពលរដ្ឋដែលជាប់ពន្ធ ត្រូវបង់ពន្ធជូនរដ្ឋ ហើយប្រាក់នេះត្រូវបញ្ជូនចូលក្នុងថវិការដ្ឋតាមរូបភាពជាក់ស្តែងផ្សេងៗគ្នា។ នេះគឺជាតួនាទីសំខាន់ៗរបស់ពន្ធដារ ហើយតួនាទីនេះចាប់ផ្តើមពីចំណុចពិសេស អំពីសិទ្ធអំណាចរបស់រដ្ឋាភិបាលក្នុងសង្គម។

រដ្ឋាភិបាល បានប្រើប្រាស់សិទ្ធអំណាចខាងរដ្ឋបាលបានដាក់ចេញនូវ ពន្ធដែលមានចែងបណ្តាប្រភេទពន្ធកម្រិតពន្ធ អត្រាពន្ធ ការណែនាំអនុវត្ត និងការកែសម្រួលផ្សេងៗ។

ក្នុងគោលនយោបាយ ពន្ធរបស់រដ្ឋាភិបាល នៃបណ្តាប្រទេសភាគច្រើន ជាទូទៅបានដាក់ចេញនូវសំណូមពរបី ដែលត្រូវឆ្លើយតប រាល់ក្រឹត្យច្បាប់ ច្បាប់សារពើរពន្ធ ត្រូវតែតាមដានថ្លឹងថ្លែងជាប្រចាំ ដើម្បីឆ្លើយតបនូវសំណូមពរទាំងឡាយ ។

ក. សំណូមពរបង្កើតប្រភពចំណូលឱ្យថវិការដ្ឋ ត្រូវបានស្តែងឡើងនូវបរិមាណពន្ធ ដែលប្រមូលបាន និងលទ្ធភាពឆ្លើយតបរបស់វារាល់តម្រូវការចំណាយរបស់រដ្ឋាភិបាល។

ខ. ដើម្បីបង្កើនប្រភពចំណូលថវិការដ្ឋ ត្រូវតែកសាងប្រព័ន្ធពន្ធមួយឱ្យបានសមស្រប គ្រប់ជ្រុងជ្រោយទៅតាមស្ថានភាពជាក់ស្តែងរបស់សេដ្ឋកិច្ចជាតិ និងទៅតាមតំបន់សេដ្ឋកិច្ច។

គ. ទន្ទឹមនោះ រដ្ឋាភិបាលត្រូវតែលើកកំពស់ប្រសិទ្ធភាព នៃប្រព័ន្ធក្បាលម៉ាស៊ីនគ្រប់គ្រង និងប្រមូលពន្ធប្រឆាំងនឹងការគេចពន្ធ លួចបន្លំពន្ធ ស៊ីសំណូក ពុករលួយ និងការប្រមូលពន្ធមិនគ្រប់ជ្រុងជ្រោយ។

២. ជម្រុញបង្កើនល្បឿនអភិវឌ្ឍន៍សេដ្ឋកិច្ច ហិរញ្ញវត្ថុ

ត្រូវបានស្តែងឡើង នូវការសាងប្រព័ន្ធសមស្របមួយ និងស្តែងឡើងនូវបណ្តាការអនុវត្តន៍ដ៏ប្រពៃរបស់ពន្ធដារ។ នៅបណ្តាប្រទេសដែលកំពុងអភិវឌ្ឍន៍ និងអន់ថយមួយចំនួនពីមុនក្នុងរយៈពេលដែលខិតខំលើកកម្ពស់អត្រាពន្ធ នៃប្រភពមួយចំនួនដូចជា៖ អាករលើផលរបរ ពន្ធលើចំណូលបុគ្គលិក ពន្ធលើប្រាក់ចំណេញ អាករពិសេស លើទំនិញ និងសេវាមួយចំនួន។ ប៉ុន្តែ មិនបានយកចិត្តទុកដាក់ដល់ប្រភេទពន្ធមួយចំនួនទៀតដូចជា៖ ពន្ធលើធនធាន ពន្ធលើដីធ្លីដែលនាំឱ្យមានការប្រើប្រាស់ធនធានពាសពេញ ឥតសណ្តាប់ធ្នាប់ និងខ្ជះខ្ជាយ។ ឧទាហរណ៍៖ ព្រៃឈើត្រូវបានគេកាប់បំផ្លាញ និងខ្ជះខ្ជាយធនធានហើយដែលជាមូលហេតុបណ្តាលឱ្យវិនាសធនធានធម្មជាតិ ដែលជាសម្បត្តិរបស់រដ្ឋ និងអាចបណ្តាលឱ្យមានគ្រោះធម្មជាតិចំពោះប្រទេសជាតិ។

៣. ទប់សម្រួលចំណូលរបស់ប្រជាពលរដ្ឋនៅក្នុងសង្គម

ពន្ធ មានតួនាទីយ៉ាងសំខាន់ក្នុងការរក្សាសមាមាត្ររវាងអ្នកមាន និងអ្នកក្រកុំឱ្យឃ្លាតឆ្ងាយពីគ្នាពេកមានន័យថា ពន្ធដារបានកាត់បន្ថយចំណូលរបស់អ្នក ដែលមានទ្រព្យធនច្រើន និងបង្កើនប្រភពចំណូលថវិកា ដើម្បីធ្វើការបែងចែកឡើងវិញឱ្យអ្នកក្រីក្រ ដោយឆ្លងកាត់តាមគោលនយោបាយចំណាយរបស់រដ្ឋាភិបាល។

រវាងអាជីវករដែលមានទ្រព្យសម្បត្តិ និងចំណូលខ្ពស់ជាមួយនឹងពលរដ្ឋក្រីក្រ ក៏មានទំនាក់ទំនងចំណុះគ្នាដើម្បីមានស្ថេរភាពក្នុងសង្គម។ មានន័យថា នៅពេលដែលមានព្រំដែនមួយ នៃការបែងចែកឡើងវិញហើយ ដែលកម្រិតយល់ដឹងយ៉ាងឆាប់រហ័សរបស់អាជីវករ នោះអាជីវករប្រជាពលរដ្ឋទាំងអស់បានត្រៀមជាស្រេចក្នុងការរួមវិភាគទានមួយផ្នែក នូវចំណូលរបស់ខ្លួនឱ្យរាល់សំណូមពររបស់សង្គម។ គេអាចកំណត់ក្របខណ្ឌព្រំដែននោះ ដោយឆ្លងកាត់តាមប្រតិកម្មរបស់បណ្ដាអង្គភាពអាជីវកម្ម ផលិតកម្ម សិប្បកម្ម សេវាកម្មនីមួយៗ។

ដើម្បីទប់សម្រួលចំណូល និងការបែងចែកឡើងវិញ នូវចំណូលរវាងបណ្ដាលស្រទាប់វណ្ណៈផ្សេងៗគ្នានៅក្នុងសង្គម ជាទូទៅរដ្ឋាភិបាលបានបង្កើតពន្ធប្រយោលចំពោះប្រភេទទំនិញ ឬសេវាមួយចំនួនរបស់មុខសញ្ញាណាដែលមានចំណូលខ្ពស់ ជំនួសឱ្យការយកពន្ធដោយផ្ទាល់។ វិធីសាស្ត្រនេះល្អ ក្នុងវិស័យគ្រប់គ្រង និងទាំងវិស័យចិត្តសាស្ត្រ ហើយងាយស្រួលនឹងបានទទួលស្គាល់។

**គ. ភារកិច្ចពន្ធដារ**

អគ្គនាយកដ្ឋានពន្ធដារ មានភារកិច្ចដូចតទៅ៖

- ចូលរួមរៀបចំគោលនយោបាយសារពើពន្ធ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល និងបរិបទអន្តរជាតិ
- រៀបចំសេចក្ដីព្រាងច្បាប់ លិខិតបទដ្ឋាន ស្ដីពីពន្ធដារកំណត់បញ្ជីឯកសារ និងលិខិតគតិយុត្តិនានា សម្រាប់ការគ្រប់គ្រងប្រមូលពន្ធ
- ប្រមូលប្រាក់ពន្ធគ្រប់ប្រភេទបង់ចូលថវិកាជាតិ
- ចុះបញ្ជីអ្នកជាប់ពន្ធ
- ផ្ដល់ការអប់រំ ដល់អ្នកជាប់ពន្ធអំពីកាតព្វកិច្ចសារពើពន្ធ ផ្ដល់សេវា និងព័ត៌មានដល់អ្នកជាប់ពន្ធ ដើម្បីបង់ពន្ធឱ្យបានត្រឹមត្រូវតាមច្បាប់ និងបទប្បញ្ញត្តិស្ដីពីពន្ធដារ
- កសាងកម្មវិធីសវនកម្ម និងធ្វើសវនកម្មលើអ្នកជាប់ពន្ធ
- កំណត់មូលដ្ឋានគិតពន្ធ ប្រាក់ពន្ធ ពន្ធបន្ថែម និងការប្រាក់យឺតយ៉ាវ ចំពោះអ្នកជាប់ពន្ធស្របតាមច្បាប់ និងបទប្បញ្ញត្តិស្ដីពីពន្ធដារ
- ស៊ើបអង្កេត បទល្មើសព្រហ្មទណ្ឌលើ បទប្បញ្ញត្តិស្ដីពីពន្ធដារ
- អនុវត្តវិធានការតឹងទារ និងទោសទណ្ឌតាមច្បាប់ ចំពោះអ្នកជាប់ពន្ធដែលប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិស្ដីពីសារពើពន្ធ
- ធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធ
- រៀបចំ និងអនុវត្តកិច្ចសហប្រតិបត្តការជាតិ និងអន្តរជាតិនានា ទាក់ទិននឹងពន្ធដារ
- រៀបចំផែនការជ្រើសរើស បណ្ដុះបណ្ដាល និងកសាងសមត្ថភាពធនធានមនុស្សទាក់ទិន និងពន្ធដារ
- ចូលរួមរៀបចំគម្រោងថវិការជាតិ និងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ។

## ៣.២ នីតិវិធីនៃការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធ

### ៣.២.១ ភាតព្វកិច្ចធ្វើបច្ចុប្បន្នភាពព័ត៌មានរបស់អ្នកជាប់ពន្ធ

អ្នកជាប់ពន្ធ ដែលបានចុះបញ្ជីពន្ធដារមានកាតព្វកិច្ចជូនដំណឹងមករដ្ឋបាលសារពើពន្ធ ក្នុងកំឡុងពេល ១៥ថ្ងៃ នៃថ្ងៃធ្វើការក្នុងករណីដែលព័ត៌មានណាមួយ ក្នុងចំណោមព័ត៌មានខាងក្រោមនេះត្រូវបានផ្លាប្តូរៈ

ក. អាសយដ្ឋាន។

ខ. ទ្រង់ទ្រាយ។

គ. នាមករណ៍។

ឃ. កម្មវត្ថុអាជីវកម្ម ឬសកម្មភាពអាជីវកម្ម។

ង. ការផ្ទេរផ្លាស់ប្តូរម្ចាស់ភាគហ៊ុន។

ច. សមាសភាពអ្នកគ្រប់គ្រងសហគ្រាស ឬសាខា។

ឆ. ការបញ្ឈប់អាជីវកម្ម។

ជ. អ្នកទទួលបន្ទុកកិច្ចការពន្ធដារ។

ឈ. ព័ត៌មានគណនីធនាគារ។

ញ. ព័ត៌មានទំនាក់ទំនង លេខទូរស័ព្ទ សារអេឡិចត្រូនិក។

1. អ្នកជាប់ពន្ធ ដែលមានការផ្លាស់ប្តូរព័ត៌មានណាមួយ ដូចមានចែងក្នុងកថាខណ្ឌ១នៃប្រកាសនេះ ត្រូវមកធ្វើបច្ចុប្បន្នភាពព័ត៌មាន ដោយត្រូវបំពេញព័ត៌មាន និងភ្ជាប់មកនូវឯកសារចុងក្រោយនៃឯកសារបញ្ជាក់ការផ្លាស់ប្តូរព័ត៌មាននោះតែប៉ុណ្ណោះ ដូចមានកំណត់ក្នុងពាក្យស្នើសុំចុះបញ្ជីពន្ធដារ និងបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ (ទម្រង់ ១០១) ចំណែកការផ្លាស់ប្តូរព័ត៌មានសាខា ឬបន្ថែមសាខា អ្នកជាប់ពន្ធត្រូវបំពេញព័ត៌មានសាខាតាមទម្រង់909-C និងភ្ជាប់ឯកសារ ដូចមានកំណត់ក្នុងឧបសម្ព័ន្ធស្តីពីឯកសារតម្រូវសម្រាប់បច្ចុប្បន្នភាពព័ត៌មាន។
2. អ្នកជាប់ពន្ធដែលបានចុះបញ្ជីពន្ធដារ ប៉ុន្តែនៅមិនទាន់មានលេខអត្តសញ្ញាណកម្មសារពើពន្ធ តាមទម្រង់ថ្មីដែលរដ្ឋបាលសារពើពន្ធបានកំណត់ ប្រធានឬអ្នកតំណាង ម្ចាស់សហគ្រាស ឬអ្នកតំណាងរបស់បុគ្គលដូចមានចែងក្នុងប្រការ៤នៃប្រកាសនេះ ត្រូវមកធ្វើបច្ចុប្បន្នភាពព័ត៌មាន ដោយត្រូវបំពេញព័ត៌មាន និងភ្ជាប់ឯកសារតម្រូវដូចមានកំណត់ក្នុងពាក្យស្នើសុំចុះបញ្ជីពន្ធដារនិងបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ (ទម្រង់១០១)។
3. តាមការចាំបាច់ ឬនៅពេលដែលរដ្ឋបាលសារពើពន្ធពិនិត្យឃើញថា អ្នកជាប់ពន្ធបានប្រើប្រាស់ព័ត៌មានមិនពិត មិនត្រឹមត្រូវ មិនគ្រប់គ្រាន់ មិនច្បាស់លាស់ ឯកសារក្លែងក្លាយ រដ្ឋបាលសារពើពន្ធអាចអញ្ជើញអ្នកជាប់ពន្ធ ដែលបានចុះបញ្ជីពន្ធដារតាមគេហទំព័រចុះបញ្ជីអាជីវកម្ម មកផ្តល់ព័ត៌មានបន្ថែម ឬមកធ្វើបច្ចុប្បន្នភាព។

ក្នុងករណីអ្នកជាប់ពន្ធមិនបានបង្ហាញខ្លួនតាមការអញ្ជើញ របស់រដ្ឋបាលសារពើពន្ធ បុគ្គលនោះនឹងត្រូវដាក់ចូលក្នុងបញ្ជីអវិជ្ជមាន សម្រាប់ការចុះបញ្ជីរបស់អគ្គនាយកដ្ឋានពន្ធដារ ហើយការចុះបញ្ជីពន្ធដារនឹងត្រូវបានបដិសេធ និងមិនត្រូវបានអនុញ្ញាតឱ្យចុះបញ្ជីអាជីវកម្មដទៃទៀតតាមគេហទំព័រចុះបញ្ជីអាជីវកម្មឡើយ។

### ៣.២.២ នីតិវិធីនៃការធ្វើបច្ចុប្បន្នភាពព័ត៌មាន

បុគ្គលស្នើសុំត្រូវបំពេញ “ពាក្យស្នើសុំចុះបញ្ជីពន្ធដារ និងបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ (ទម្រង់ ១០១)” និងភ្ជាប់ឯកសារតម្រូវទៅតាមទ្រង់ទ្រាយគតិយុត្ត។

| លរ | ទ្រង់ទ្រាយ | ផ្នែក |
|---|---|---|
| ១ | ស្ថាប័នរដ្ឋ បេសកកម្មទូត កុងស៊ុលបរទេស អង្គការអន្តរជាតិ ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា គណបក្សនយោបាយ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ។ | 101-P1 |
| ២ | ក្រុមហ៊ុនមូលធន (ក្រុមហ៊ុនឯកជន /មហាជនទទួលខុសត្រូវមានកម្រិត) | 101-P2 |
| ៣ | ក្រុមហ៊ុនបរទេស (សាខាក្រុមហ៊ុន/ការិយាល័យតំណាង) | 101-P3 |
| ៤ | ក្រុមហ៊ុនសហកម្មសិទ្ធិ (សហកម្មសិទ្ធិទូទៅមានកម្រិត) | 101-P4 |
| ៥ | សគ្រាសឯកបុគ្គល និងបុគ្គលប្រកបអាជីវកម្មដទៃទៀត | 101-P5 |

១. ដាក់លិខិតជូនដំណឹង ទៅសាមីអង្គភាពគ្រប់គ្រង ឬនាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅដោយៈ

បំពេញពាក្យស្នើសុំចុះបញ្ជីពន្ធដារ និងបច្ចុប្បន្នភាពព័ត៌មានរបស់អ្នកជាប់ពន្ធ (ទម្រង់ ១០១ ) នៅផ្នែកដែលមានព័ត៌មានត្រូវផ្លាស់ប្តូរ

- ភ្ជាប់ឯកសារតាមឧបសម្ព័ន្ធ ស្តីពីឯកសារតម្រូវសម្រាប់បច្ចុប្បន្នភាពព័ត៌មាន
- បង់កម្រៃសេវា ឬ/និងពន្ធប៉ាតង់ ស្របតាមសម្ព័ន្ធស្តីពីកម្រៃសេវាសាធារណៈ និងពន្ធប៉ាតង់ ។

២. អ្នកជាប់ពន្ធធំ អ្នកជាប់ពន្ធមធ្យម និងអ្នកជាប់ពន្ធតូច ដែលជាសហគ្រាសអាជីវកម្ម ឬបុគ្គលដូចមានចែងក្នុងវាក្យខណ្ឌ ខ និងវាក្យខណ្ឌ ឃ នៃកថាខណ្ឌ១ នៃប្រការ៤ នៃប្រកាសនេះ

- វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ (អាករលើតម្លៃបន្ថែម អតប)
- ប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារនុភាព
- ប័ណ្ណពន្ធប៉ាតង់
- លិខិតជូនដំណឹងស្តីពីការបំពេញកាតព្វកិច្ចសារពើពន្ធ។

៣. អ្នកជាប់ពន្ធដទៃទៀត ឬអ្នកជាប់ពន្ធដែលមានកម្រិតផលរបរទាប ជាងអ្នកជាប់ពន្ធតូច

- លិខិតបញ្ជាក់ការចុះបញ្ជីពន្ធដារ
- ប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ(កាត)។

៤. ក្រោយពេលទទួលបានការសម្រេចឱ្យចុះបញ្ជីពន្ធដារ ឬធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ រដ្ឋបាលសារពើពន្ធអាចចុះដល់ទីតាំងអ្នកជាប់ពន្ធ ដើម្បីប្រគល់ឯកសារផ្លូវការ ដែលបានចេញដោយរដ្ឋបាលសារពើពន្ធ និងពិនិត្យផ្ទៀងផ្ទាត់ចំណុចនិយាម ថតរូបទីតាំង និងកត់ត្រាទិន្នន័យទីតាំងផ្សេងៗរបស់អ្នកជាប់ពន្ធចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធដារ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
អគ្គនាយកដ្ឋានពន្ធដារ
GENERAL DEPARTMENT OF TAXATION

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

ទម្រង់ ១០១ / FORM 101

## ពាក្យស្នើសុំចុះបញ្ជីពន្ធដារ និងបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ

APPLICATION FORM FOR TAX REGISTRATION / TAXPAYER INFORMATION UPDATE

### I- កាតព្វកិច្ចចុះបញ្ជី/បច្ចុប្បន្នភាពព័ត៌មាន / OBLIGATION OF REGISTRATION/UPDATE INFORMATION

ស្នើសុំ៖ Apply for:

☐ ចុះបញ្ជីពន្ធដារ Tax registration ▶ សូមបំពេញព័ត៌មាន និងភ្ជាប់ឯកសារទៅតាមផ្នែកនៃទម្រង់គតិយុត្តនីមួយៗ
Please fill out the information and attach the documents required by following each part of the legal form

☐ បច្ចុប្បន្នភាពព័ត៌មាន Information Update ▶ សូមបំពេញព័ត៌មានតាមផ្នែកដែលមានការផ្លាស់ប្តូរ និងភ្ជាប់ឯកសារតាមឧបសម្ព័ន្ធស្តីពីឯកសារតម្រូវសម្រាប់បច្ចុប្បន្នភាពព័ត៌មាន
Please fill out the information that have been updated in the relevant sections and attach the documents required by following the "Annex on Requirement Documents for Information Update"

សម្គាល់៖ Note:

| | ទម្រង់គតិយុត្ត / LEGAL FORM | ផ្នែក/PART |
|---|---|---|
| ☐ | 1. ស្ថាប័នរដ្ឋ បេសកកម្មទូត កុងស៊ុលបរទេស អង្គការអន្តរជាតិ ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា គណបក្សនយោបាយ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល /State Institution, Diplomatic Mission, Foreign Consulate, International Organization, Technical Cooperation Agency of Other Governments, Political Party, Association and Non-government Organization | 101-P1 |
| ☐ | 2. ក្រុមហ៊ុនមូលធន (ក្រុមហ៊ុនឯកជន/មហាជនទទួលខុសត្រូវមានកម្រិត) /Limited Company (Private / Public Limited Company) | 101-P2 |
| ☐ | 3. ក្រុមហ៊ុនបរទេស (សាខាក្រុមហ៊ុន/ការិយាល័យតំណាង) /Foreign Company (Branch / Representative Office) | 101-P3 |
| ☐ | 4. ក្រុមហ៊ុនសហកម្មសិទ្ធិ (ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ/មានកម្រិត) /Partnership Company (General Partnership / Limited Partnership Company) | 101-P4 |
| ☐ | 5. សហគ្រាសឯកបុគ្គល និងបុគ្គលប្រកបអាជីវកម្មដទៃទៀត /Sole Proprietorship /Others | 101-P5 |

### II- ព័ត៌មានអ្នកបំពេញពាក្យស្នើសុំ / PREPARER INFORMATION

តើអ្នកមានទំនាក់ទំនងអ្វីជាមួយនឹងបុគ្គលស្នើសុំ? What is your relation to the applicant? ☐ ភ្នាក់ងារ/ផ្សេងៗ Agent/Other

☐ ប្រធាន/អ្នកតំណាងស្ថាប័ន Head of Institution/Representative ☐ កម្មសិទ្ធិករ/ម្ចាស់ភាគហ៊ុន Owner/Shareholder ☐ ក្រុមប្រឹក្សាភិបាល Board of Directors

លេខអត្តសញ្ញាណកម្មពន្ធរូបវន្តបុគ្គល (ប្រសិនបើមាន) Physical Person Tax Identification Number (If any)

ភេទ Sex ☐ ប្រុស Male ☐ ស្រី Female

គោត្តនាម Last Name

នាម First Name

អក្សរឡាតាំង (គោត្តនាម-នាម) In Latin (Last-name, First-name)

ថ្ងៃខែឆ្នាំកំណើត Date of Birth

សញ្ជាតិ Nationality

☐ លេខអត្តសញ្ញាណប័ណ្ណ Identification Card Number ☐ លេខលិខិតឆ្លងដែន Passport Number

ថ្ងៃខែឆ្នាំផ្តល់ Issued Date

ថ្ងៃខែឆ្នាំផុតកំណត់ Date of Expiry

ទូរស័ព្ទចល័ត Mobile Phone Number

សារអេឡិចត្រូនិក Email Address

35mm

Min 32mm Max 36mm

45mm

រូបថត PHOTO

ហត្ថលេខា/ស្នាមមេដៃស្តាំ ម្ចាស់ខ្លួន Signature / Right-thumb Print of owner

Signature/Right-Thumb Print and Name

ឈ្មោះស្ថាប័ន/សហគ្រាសជាអក្សរខ្មែរ Name of Institution/Enterprise in Khmer ----------
ឈ្មោះជាឡាតាំង Name in Latin ----------

## ឧបសម្ព័ន្ធស្ដីពីឯកសារតម្រូវសម្រាប់បច្ចុប្បន្នភាពព័ត៌មាន
ANNEX ON REQUIREMENT DOCUMENTS FOR INFORMATION UPDATE

សម្គាល់៖
Note:

| ទ្រង់ទ្រាយគតិយុត្ត<br>LEGAL FORM | |
|---|---|
| 1. ស្ថាប័នរដ្ឋ បេសកកម្មទូត កុងស៊ុលបរទេស អង្គការអន្តរជាតិ ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា គណបក្សនយោបាយ សមាគម និង អង្គការមិនមែនរដ្ឋាភិបាល /State Institution, Diplomatic Mission, Foreign Consulate, International Organization, Technical Cooperation Agency of other Government, Political Party, Association and Non-government Organization | P1 |
| 2. ក្រុមហ៊ុនមូលធន (ក្រុមហ៊ុនឯកជន/មហាជនទទួលខុសត្រូវមានកម្រិត) /Limited Company (Private / Public Limited Company) | P2 |
| 3. ក្រុមហ៊ុនបរទេស (សាខាក្រុមហ៊ុន/ការិយាល័យតំណាង) /Foreign Company (Branch / Representative office) | P3 |
| 4. ក្រុមហ៊ុនសហកម្មសិទ្ធិ (ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ/មានកម្រិត) /Partnership Company (General Partnership / Limited Partnership Company) | P4 |
| 5. សហគ្រាសឯកបុគ្គល និងបុគ្គលប្រកបអាជីវកម្មដទៃទៀត /Sole Proprietorship / Others | P5 |

## បញ្ជីឯកសារតម្រូវតាមការផ្លាស់ប្ដូរព័ត៌មាន
LIST OF REQUIREMENT DOCUMENTS FOR INFORMATION UPDATE

| លរ<br>No. | បរិយាយ<br>Description | ទ្រង់ទ្រាយគតិយុត្ត<br>Legal Form | | | | |
|---|---|---|---|---|---|---|
| | | P1 | P2 | P3 | P4 | P5 |
| 1- | ការស្នើសុំផ្លាស់ប្ដូរអាសយដ្ឋាន /Request for updating address | | | | | |
| | លិខិតជូនដំណឹងទៅសាមីអង្គភាពគ្រប់គ្រង ឬនាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ<br>Notification Letter attended by any Tax Administration Unit or Department of Administration and General Affairs | ✓ | ✓ | ✓ | ✓ | ✓ |
| | ពាក្យស្នើសុំចុះបញ្ជីពន្ធដារនិងបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ (ទម្រង់ 101) នៅផ្នែកដែលមានព័ត៌មានត្រូវផ្លាស់ប្ដូរ<br>Application for Tax Registration and Taxpayer Information Update (Form 101) at any updated information section | ✓ | ✓ | ✓ | ✓ | ✓ |
| | លិខិតបញ្ជាក់ការចុះបញ្ជី ឬលិខិតអនុញ្ញាត ចេញដោយរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័នពាក់ព័ន្ធ<br>Confirmation of Registration Letter or Permit Letter issued by The Royal Government or relevant ministries/institutions | ✓ | ✓ | ✓ | ✓ | បើមាន (If any) |
| | ប័ណ្ណកម្មសិទ្ធិទីតាំង ឬកិច្ចសន្យាជួលទីតាំង ដែលមានព័ត៌មានចំណុចនិយាមការទីតាំងរបស់ទីស្នាក់ការឬទីតាំងការសហគ្រាស<br>Title deed or rental agreement of the property with the geographical coordinates of the business address<br>* ទីតាំងដែលគ្មានអគារ ឬជាដីទំនេរ ឬមានសំណង់ទើបតែសាងសង់ដែលមិនអាចប្រើប្រាស់បាន មិនត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់សម្រាប់ការចុះបញ្ជីពន្ធដារបានឡើយ លើកលែងតែមានការយល់ព្រមពីអគ្គនាយកដ្ឋានពន្ធដារ /Business address without building or vacant land or unusable building in progress of construction is not allowed to use as registered address unless there is approval from the General Department of Taxation | ✓ | ✓ | ✓ | ✓ | ✓ |
| 2- | ការស្នើសុំផ្លាស់ប្ដូរទ្រង់ទ្រាយគតិយុត្ត /Request for updating legal form | | | | | |
| | លិខិតជូនដំណឹងទៅសាមីអង្គភាពគ្រប់គ្រង ឬនាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ<br>Notification Letter attended by any Tax Administration Unit or Department of Administration and General Affairs | ✓ | ✓ | ✓ | ✓ | ✓ |
| | ពាក្យស្នើសុំចុះបញ្ជីពន្ធដារនិងបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ (ទម្រង់ 101) នៅផ្នែកដែលមានព័ត៌មានត្រូវផ្លាស់ប្ដូរ<br>Application for Tax Registration and Taxpayer Information Update (Form 101) at any updated information section | ✓ | ✓ | ✓ | ✓ | ✓ |
| | លិខិតបញ្ជាក់ការចុះបញ្ជី ឬលិខិតអនុញ្ញាត ចេញដោយរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័នពាក់ព័ន្ធ<br>Confirmation of Registration Letter or Permit Letter issued by The Royal Government or relevant ministries/institutions | ✓ | ✓ | ✓ | ✓ | បើមាន (If any) |
| 3- | ការស្នើសុំផ្លាស់ប្ដូរនាមករណ៍/Request for updating name | | | | | |
| | លិខិតជូនដំណឹងទៅសាមីអង្គភាពគ្រប់គ្រង ឬនាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ<br>Notification Letter attended by any Tax Administration Unit or Department of Administration and General Affairs | ✓ | ✓ | ✓ | ✓ | ✓ |
| | ពាក្យស្នើសុំចុះបញ្ជីពន្ធដារនិងបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ (ទម្រង់ 101) នៅផ្នែកដែលមានព័ត៌មានត្រូវផ្លាស់ប្ដូរ<br>Application for Tax Registration and Taxpayer Information Update (Form 101) at any updated information section | ✓ | ✓ | ✓ | ✓ | ✓ |
| | លិខិតបញ្ជាក់ការចុះបញ្ជី ឬលិខិតអនុញ្ញាត ចេញដោយរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័នពាក់ព័ន្ធ<br>Confirmation of Registration Letter or Permit Letter issued by The Royal Government or relevant ministries/institutions | ✓ | ✓ | ✓ | ✓ | បើមាន (If any) |

ទំព័រ 1/3

## ឧបសម្ព័ន្ធស្ដីពីឯកសារតម្រូវសម្រាប់បច្ចុប្បន្នភាពព័ត៌មាន
## ANNEX ON REQUIREMENT DOCUMENTS FOR INFORMATION UPDATE

| ល.រ No. | បរិយាយ Description | ទម្រង់គតិយុត្ត Legal Form P1 | P2 | P3 | P4 | P5 |
|---|---|---|---|---|---|---|
| 4- | ការស្នើសុំផ្លាស់ប្ដូរឬបន្ថែម បេសកកម្ម/សកម្មភាពអាជីវកម្ម /Request for updating or adding mission/business activities | | | | | |
| | លិខិតជូនដំណឹងទៅសាមីអង្គភាពគ្រប់គ្រង ឬនាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ<br>Notification Letter attended by any Tax Administration Unit or Department of Administration and General Affairs | ✓ | ✓ | ✓ | ✓ | ✓ |
| | ករណីផ្លាស់ប្ដូរសកម្មភាពអាជីវកម្មចម្បង៖ ពាក្យស្នើសុំចុះបញ្ជីពន្ធដារនិងបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ (ទម្រង់ 101) នៅផ្នែកដែលមានព័ត៌មានត្រូវផ្លាស់ប្ដូរ /In case of any update of the main business activity: Application for Tax Registration and Taxpayer Information Update (Form 101) at any updateed section<br>ឬ ករណីបន្ថែមសកម្មភាពអាជីវកម្មបន្ទាប់បន្សំ៖ ទម្រង់ព័ត៌មានបេសកកម្ម/សកម្មភាពអាជីវកម្ម (ទម្រង់ 101-D)<br>Or in case of any update of supporting activities: Mission/business activity information form (Form 101-D) | ✓ | ✓ | ✓ | ✓ | ✓ |
| 5- | ការស្នើសុំការផ្ទេរ ឬផ្លាស់ប្ដូរម្ចាស់ភាគហ៊ុន ប្រធានក្រុមប្រឹក្សាភិបាល អភិបាល ឬអ្នកតំណាង /Request for transfer share/contribution/capital or updating shareholders, Chairman of The board of directors, director, manager or representative | | | | | |
| | លិខិតជូនដំណឹងទៅសាមីអង្គភាពគ្រប់គ្រង ឬនាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ<br>Notification Letter attended by any Tax Administration Unit or Department of Administration and General Affairs | ✓ | ✓ | ✓ | ✓ | ✓ |
| | ទម្រង់ព័ត៌មានរូបវន្តបុគ្គល (ទម្រង់ 101-B) /Physical person information form (Form 101-B) | ✓ | ✓ | ✓ | ✓ | ✓ |
| | លិខិតបញ្ជាក់ការចុះបញ្ជី ឬលិខិតអនុញ្ញាត ចេញដោយរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័នពាក់ព័ន្ធ<br>Confirmation of Registration Letter or Permit Letter issued by The Royal Government or relevant ministries/institutions | ✓ | ✓ | ✓ | ✓ | បើមាន (If any) |
| | អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន ដែលមានសុពលភាពរបស់ប្រធានស្ថាប័ន ឬអ្នកតំណាង។<br>Valid Cambodian identification card or passport of head of Institution or representative<br>* រូបវន្តបុគ្គលដែលជាកម្មវត្ថុក្នុងការបំពេញព័ត៌មានក្នុងពាក្យស្នើសុំនេះ ដែលមានអាសយដ្ឋានស្នាក់នៅបច្ចុប្បន្នខុសពីអាសយដ្ឋានក្នុងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនត្រូវភ្ជាប់បន្ថែមនូវសៀវភៅគ្រួសារឬសៀវភៅស្នាក់នៅ ឬលិខិតបញ្ជាក់ការស្នាក់នៅដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច /Physical persons who are subject to fill out their information in this application form, who have different current address from address in Identification card or Passport, shall enclosed their Family's record or Resident Record or Letter of Resident certified by local authority | ✓ | ✓ | ✓ | ✓ | ✓ |
| | រូបថតបច្ចុប្បន្នមិនលើសពីរយៈពេល ០៣ខែ ដែលមានទំហំ ៣៥ x ៤៥មិល្លីម៉ែត្រ និងមានផ្ទៃខាងក្រោយពណ៌ស ចំនួន ០២ សន្លឹក របស់ប្រធានស្ថាប័ន ក្រុមប្រឹក្សាភិបាល អភិបាល ម្ចាស់ភាគហ៊ុន អ្នកគ្រប់គ្រង ឬអ្នកតំណាង<br>Two current photos taken no more than 3 months ago with size 35 x 45 mm and white background of head of institution, chairman of the board of directors, shareholders, managers or representatives | ✓ | ✓ | ✓ | ✓ | ✓ |
| 6- | ស្នើសុំផ្លាស់ប្ដូរសមាសភាពអ្នកគ្រប់គ្រងសាខា ឬបន្ថែមសាខា /Request for updating branch managers or adding branch | | | | | |
| | លិខិតជូនដំណឹងទៅសាមីអង្គភាពគ្រប់គ្រង ឬនាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ<br>Notification Letter attended by any Tax Administration Unit or Department of Administration and General Affairs | ✓ | ✓ | ✓ | ✓ | ✓ |
| | ទម្រង់ព័ត៌មានសាខា (ទម្រង់ 101-C) /Branch information form (Form 101-C) | ✓ | ✓ | ✓ | ✓ | ✓ |
| | លិខិតបញ្ជាក់ការចុះបញ្ជី ឬលិខិតអនុញ្ញាត ចេញដោយរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័នពាក់ព័ន្ធ<br>Confirmation of Registration Letter or Permit Letter issued by The Royal Government or relevant ministries/institutions | ✓ | ✓ | ✓ | ✓ | បើមាន (If any) |
| | អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន ដែលមានសុពលភាពរបស់អ្នកគ្រប់គ្រងសាខា។<br>Valid Cambodian identification card or passport of branch manager<br>* រូបវន្តបុគ្គលដែលជាកម្មវត្ថុក្នុងការបំពេញព័ត៌មានក្នុងពាក្យស្នើសុំនេះ ដែលមានអាសយដ្ឋានស្នាក់នៅបច្ចុប្បន្នខុសពីអាសយដ្ឋានក្នុងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនត្រូវភ្ជាប់បន្ថែមនូវសៀវភៅគ្រួសារឬសៀវភៅស្នាក់នៅ ឬលិខិតបញ្ជាក់ការស្នាក់នៅដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច /Physical persons who are subject to fill out their information in this application form, who have different current address from address in Identification Card or Passport, shall enclosed their Family's record or Resident Record or Letter of Resident certified by local authority | ✓ | ✓ | ✓ | ✓ | ✓ |
| | រូបថតបច្ចុប្បន្នមិនលើសពីរយៈពេល ០៣ខែ ចំនួន ០២ សន្លឹក ដែលមានទំហំ ៣៥ x ៤៥មិល្លីម៉ែត្រ និងមានផ្ទៃខាងក្រោយពណ៌ស របស់អ្នកគ្រប់គ្រងសាខា /Two current photos taken not more than 3 months with size 35 x 45 mm and white background of branch manager | ✓ | ✓ | ✓ | ✓ | ✓ |
| | ប័ណ្ណកម្មសិទ្ធិទីតាំង ឬកិច្ចសន្យាជួលទីតាំង ដែលមានព័ត៌មានចំណុចនិយាមការទីតាំងរបស់ទីស្នាក់ការឬទីចាត់ការសហគ្រាស<br>Title deed or rental agreement of the property with the geographical coordinates of the business address<br>* ទីតាំងដែលគ្មានអគារ ឬជាដីទំនេរ ឬមានសំណង់ទើបតែសាងសង់ដែលមិនអាចប្រើប្រាស់បាន មិនត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ស[illegible] ការចុះបញ្ជីពន្ធដារបានឡើយ វៀរលែងតែមានការយល់ព្រមពីអគ្គនាយកដ្ឋានពន្ធដារ /Business address without a building or vacant [illegible] unusable building in progress of construction is not allowed to use as the registered address unless there is approval from the General Department of Taxation | ✓ | ✓ | ✓ | ✓ | ✓ |

ទំព័រ 2/3

# ឧបសម្ព័ន្ធស្តីពីឯកសារតម្រូវសម្រាប់បច្ចុប្បន្នភាពព័ត៌មាន
ANNEX ON REQUIREMENT DOCUMENTS FOR INFORMATION UPDATE

| លរ<br>No. | បរិយាយ<br>Description | ទម្រង់គតិយុត្ត<br>Legal Form | | | | |
|---|---|---|---|---|---|---|
| | | P1 | P2 | P3 | P4 | P5 |
| 7- | ការស្នើសុំបញ្ឈប់អាជីវកម្មជាស្ថាពរ / Request for cessation of business | | | | | |
| | លិខិតជូនដំណឹងទៅសាមីអង្គភាពគ្រប់គ្រង ឬនាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ<br>Notification Letter attended by any Tax Administration Unit or Department of Administration and General Affairs | ✓ | ✓ | ✓ | ✓ | ✓ |
| | ពាក្យស្នើសុំបញ្ឈប់អាជីវកម្ម /Application Form for cessation of business | ✓ | ✓ | ✓ | ✓ | ✓ |
| | លិខិតប្រកាសសារពើពន្ធប្រចាំខែ ៣ ខែចុងក្រោយ ករណីអ្នកជាប់ពន្ធបានចុះបញ្ជីពន្ធដាររួចរាល់<br>Monthly tax returns of the last 3 months as a registered taxpayer | ✓ | ✓ | ✓ | ✓ | ✓ |
| | លិខិតប្រកាសពន្ធលើប្រាក់ចំណូល ឆ្នាំស្នើសុំបញ្ឈប់អាជីវកម្ម ករណីអ្នកជាប់ពន្ធបានចុះបញ្ជីពន្ធដាររួចរាល់<br>Tax on income returns for the year of business cessation request as a registered taxpayer | ✓ | ✓ | ✓ | ✓ | ✓ |
| | លិខិតជូនដំណឹងស្តីពីការផ្ទេរសិទ្ធិដល់បុគ្គលទទួលបន្ទុកកិច្ចការពន្ធដារ /Authorization letter for the person in charge of tax matters<br>* ប្រសិនបើមានអ្នកទទួលបន្ទុកជំនួស /If have any authorized person | ✓ | ✓ | ✓ | ✓ | ✓ |
| | អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន ដែលមានសុពលភាពរបស់អ្នកទទួលបន្ទុកកិច្ចការពន្ធដារ/តំណាងអ្នកជាប់ពន្ធ<br>Valid Cambodian identification card or passport of person in charge of tax matters/representative | ✓ | ✓ | ✓ | ✓ | ✓ |
| 8- | ស្នើសុំផ្លាស់ប្តូរអ្នកទទួលបន្ទុកកិច្ចការពន្ធដារ/តំណាងអ្នកជាប់ពន្ធ / Request for updating person in charge of tax matters/representative | | | | | |
| | លិខិតជូនដំណឹងទៅសាមីអង្គភាពគ្រប់គ្រង ឬនាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ<br>Notification Letter attended by any Tax Administration Unit or Department of Administration and General Affairs | ✓ | ✓ | ✓ | ✓ | ✓ |
| | លិខិតជូនដំណឹងស្តីពីការផ្ទេរសិទ្ធិដល់បុគ្គលទទួលបន្ទុកកិច្ចការពន្ធដារ<br>Authorization letter for Person in Charge of Tax Matters | ✓ | ✓ | ✓ | ✓ | ✓ |
| | ករណីរូបវន្តបុគ្គលទទួលសិទ្ធិ៖ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន ដែលមានសុពលភាពរបស់អ្នកទទួលបន្ទុកកិច្ចការពន្ធដារ/តំណាងអ្នកជាប់ពន្ធ<br>In case, physical person is authorized: Valid Cambodian identification card or Passport of person in charge of tax matters/representative<br>ឬករណីនីតិបុគ្គលទទួលសិទ្ធិ៖ វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ (អាករលើតម្លៃបន្ថែម-អតប)<br>or in case, legal entity is authorized: Certificate of Tax Registration (Value Added Tax-VAT) | ✓ | ✓ | ✓ | ✓ | ✓ |
| 9- | ព័ត៌មានគណនីធនាគារ /Bank account information | | | | | |
| | លិខិតជូនដំណឹងទៅសាមីអង្គភាពគ្រប់គ្រង ឬនាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ<br>Notification Letter attended by any Tax Administration Unit or Department of Administration and General Affairs | ✓ | ✓ | ✓ | ✓ | ✓ |
| | ទម្រង់ព័ត៌មានគណនីធនាគារ (ទម្រង់ 101-A) /Bank account information form ( Form 101-A) | ✓ | ✓ | ✓ | ✓ | ✓ |
| | លិខិតបញ្ជាក់ព័ត៌មានគណនីធនាគារ របស់ស្ថាប័ន សហគ្រាសអាជីវកម្ម ដែលចេញដោយធនាគារ (លិខិតបញ្ជាក់គណនីធនាគារ របាយការណ៍ធនាគារ ឬសៀវភៅគណនីធនាគារ) /Certified letter issued by bank on Institution/business's bank account information (bank confirmation letter or bank statement or bank passbook) | ✓ | ✓ | ✓ | ✓ | ✓ |
| 10- | ការស្នើសុំផ្លាស់ប្តូរព័ត៌មានទំនាក់ទំនង លេខទូរស័ព្ទ សារអេឡិចត្រូនិក /Request for updating contact information, phone number, email | | | | | |
| | លិខិតជូនដំណឹងទៅសាមីអង្គភាពគ្រប់គ្រង ឬនាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ<br>Notification Letter attended by any Tax Administration Unit or Department of Administration and General Affairs | ✓ | ✓ | ✓ | ✓ | ✓ |
| | ពាក្យស្នើសុំចុះបញ្ជីពន្ធដារនិងបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ (ទម្រង់ 101) នៅផ្នែកដែលមានព័ត៌មានត្រូវផ្លាស់ប្តូរ<br>Application for Tax Registration and Taxpayer Information Update (Form 101) at any updated information section | ✓ | ✓ | ✓ | ✓ | ✓ |

**សម្គាល់៖**
Note:

* ចំពោះការស្នើសុំផ្លាស់ប្តូរ ឬបន្ថែមព័ត៌មានចាប់ពីចំណុច "1" ដល់ចំណុច "6" ដែលរដ្ឋបាលសារពើពន្ធត្រូវផ្តល់ជូនឡើងវិញនូវវិញ្ញាបនបត្រចុះបញ្ជីពន្ធដារ ឬវិញ្ញាបនបត្រចុះបញ្ជីពន្ធដារ (អាករលើតម្លៃបន្ថែម-អតប) ឬលិខិតបញ្ជាក់ការចុះបញ្ជីសាខា ឬលិខិតបញ្ជាក់ការចុះបញ្ជីពន្ធដារ អ្នកជាប់ពន្ធត្រូវបង់កម្រៃសេវាធ្វើបច្ចុប្បន្នភាពព័ត៌មាន /For applying to change or modify any information from point 1 to 6, which requires the Tax Administration to reissue Certificate of Tax Registration or Certificate of Tax Registration (Value Added Tax-VAT) or Certificate of Branch Registration or Certified Letter of Tax Registration, the taxpayer shall pay for the information update fees

ទំព័រ 3/3

### ៣.២.៣ កម្រៃសេវា ការបង់ពន្ធប៉ាតង់និងពន្ធប្រថាប់ត្រាលើឯកសារ

កម្រៃសេវា ធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធដូចមានចែងក្នុងកថាខណ្ឌ៣ នៃប្រការ៥នៃប្រកាសនេះមានដូចខាងក្រោម៖

ក. ០ រៀល សម្រាប់ស្ថាប័នរដ្ឋ បេសកកម្មទូត កុងស៊ុលបរទេស អង្គការអន្តរជាតិ ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា និងគណបក្សនយោបាយ។

ខ. ១០ ០០០ រៀល សម្រាប់បុគ្គលដូចមានចែងក្នុងវាក្យខណ្ឌ ខ និងវាក្យខណ្ឌ ឃ នៃកថាខណ្ឌ១ នៃ ប្រការ៤ នៃប្រកាសនេះ ដែលបានចុះបញ្ជីពន្ធដារជាអ្នកជាប់ពន្ធតូច ឬអ្នកជាប់ពន្ធដែលមាន កម្រិតផលរបរទាបជាងអ្នកជាប់ពន្ធតូច។

គ. ២០០ ០០០ រៀល សម្រាប់បុគ្គលដូចមានចែងក្នុងវាក្យខណ្ឌ ខ ដល់វាក្យខណ្ឌ ឃ នៃកថាខណ្ឌ ១ នៃប្រការ៤ នៃប្រកាសនេះ ដែលបានចុះបញ្ជីពន្ធដារជាអ្នកជាប់ពន្ធមធ្យម ឬអ្នកជាប់ពន្ធធំ។

កម្រៃសេវា ដូចមានចែងក្នុងកថាខណ្ឌ២ នៃប្រការនេះ ត្រូវអនុវត្តផងដែរចំពោះ៖

ក. ការស្នើសុំផ្លាស់ប្តូរព័ត៌មានដូចមានចែងក្នុងវាក្យខណ្ឌ ក ដល់វាក្យខណ្ឌ ច នៃកថាខណ្ឌ១ នៃប្រការ៥នៃប្រកាសនេះ ដែលរដ្ឋបាលសារពើពន្ធត្រូវផ្តល់ជូនឡើងវិញ នូវវិញ្ញាបនបត្រចុះបញ្ជីពន្ធដារ ឬវិញ្ញាបនបត្រចុះបញ្ជីពន្ធដារ(អាករលើតម្លៃបន្ថែម-អតប) ឬលិខិតបញ្ជាក់ការចុះបញ្ជីសាខា ឬលិខិតបញ្ជាក់ការចុះបញ្ជីពន្ធដារ។

ខ. ការស្នើសុំ ផ្លាស់ប្តូរព័ត៌មាន ឬបន្ថែមសាខា ដែលរដ្ឋបាលសារពើពន្ធត្រូវផ្តល់ជូនឡើងវិញ ឬផ្តល់ជូនបន្ថែមនូវលិខិតបញ្ជាក់ការចុះបញ្ជីសាខា អ្នកជាប់ពន្ធត្រូវបង់កម្រៃសេវា ធ្វើបច្ចុប្បន្នភាពព័ត៌មានទៅតាមចំនួនសាខានីមួយៗដែលបានស្នើសុំ។

គ. ការស្នើសុំ បោះពុម្ពឡើងវិញនូវវិញ្ញាបនបត្រចុះបញ្ជីពន្ធដារ ឬវិញ្ញាបនបត្រចុះបញ្ជីពន្ធដារ (អាករលើតម្លៃបន្ថែម-អតប) ឬលិខិតបញ្ជាក់ការចុះបញ្ជីសាខា ឬលិខិតបញ្ជាក់ការចុះបញ្ជីពន្ធដារ។ ដោយឡែកការស្នើសុំ បោះពុម្ពប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ (កាត) អ្នកជាប់ពន្ធត្រូវបានតម្រូវឱ្យបង់កម្រៃសេវាចំនួន ៥ ០០០ រៀល។

## ឧបសម្ព័ន្ធស្តីពីកម្រៃសេវាសាធារណៈនិងពន្ធប៉ាតង់
ANNEX ON PUBLIC SERVICE FEES AND PATENT TAX

| ទ្រង់ទ្រាយគតិយុត្ត Legal form | ពន្ធប៉ាតង់ Patent Tax | កម្រៃសេវាសាធារណៈ Public service fee | | | | សរុប Total Amount |
|---|---|---|---|---|---|---|
| | | ច.ពន្ធដារ Tax registration | ប.នាមករណ៍ Name reservation | ច.ពាណិជ្ជកម្ម Biz registration | ប្រ.បើកសហគ្រាស Enterprise estab. | |
| **P1- ស្ថាប័នរដ្ឋ ស្ថាប័នបរទេស គណបក្សនយោបាយ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល** State Institution, Foreign Consulate, Political Party, Association and Non-government Organization | | | | | | |
| ● ស្ថាប័នរដ្ឋ បេសកកម្មទូត កុងស៊ុលបរទេស អង្គការអន្តរជាតិ ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា គណបក្សនយោបាយ / State Institution, Diplomatic Mission, Foreign Consulate, International Organization, Technical Cooperation Agency of other Government, Political Party | | | | | | - |
| ● សមាគម និងអង្គការមិនមែនរដ្ឋាភិបាល Association and Non-government Organization | - | 400,000 | - | - | - | 400,000 |
| **P2- ក្រុមហ៊ុនមូលធន (ក្រុមហ៊ុនឯកជន/មហាជនទទួលខុសត្រូវមានកម្រិត)** Limited Company (Private / Public Limited Company) | | | | | | |
| ● អ្នកជាប់ពន្ធធំមានផលរបរលើសពី ១០ ពាន់លានរៀល/ឆ្នាំ / Large taxpayer turnover more than 10,000 Million KHR/year | 2,500,000 | 400,000 | 25,000 | 1,010,000 | 120,000 | 4,055,000 |
| ● អ្នកជាប់ពន្ធធំ / Large taxpayer | 1,500,000 | 400,000 | 25,000 | 1,010,000 | 120,000 | 3,055,000 |
| ● អ្នកជាប់ពន្ធមធ្យម / Medium taxpayer | 600,000 | 400,000 | 25,000 | 1,010,000 | 120,000 | 2,155,000 |
| **P3- ក្រុមហ៊ុនបរទេស (សាខា/ការិយាល័យតំណាង)** Foreign Company (Branch/Representative Office) | | | | | | |
| ● អ្នកជាប់ពន្ធធំមានផលរបរលើសពី ១០ ពាន់លានរៀល/ឆ្នាំ-សាខាក្រុមហ៊ុនបរទេស/Large taxpayer turnover more than 10,000 Million KHR/year-foreign company branch | 2,500,000 | 400,000 | 25,000 | 1,010,000 | 120,000 | 4,055,000 |
| ● អ្នកជាប់ពន្ធធំ-សាខាក្រុមហ៊ុនបរទេស Large taxpayer-foreign company branch | 1,500,000 | 400,000 | 25,000 | 1,010,000 | 120,000 | 3,055,000 |
| ● អ្នកជាប់ពន្ធមធ្យម-ការិយាល័យតំណាង Medium taxpayer-representative office | 600,000 | 400,000 | 25,000 | 1,010,000 | 120,000 | 2,155,000 |
| **P4- ក្រុមហ៊ុនសហកម្មសិទ្ធិ (ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ/មានកម្រិត)** Partnership Company (General Partnership / Limited Partnership Company) | | | | | | |
| ● អ្នកជាប់ពន្ធធំមានផលរបរលើសពី ១០ ពាន់លានរៀល/ឆ្នាំ / Large taxpayer turnover more than 10,000 Million KHR/year | 2,500,000 | 400,000 | 25,000 | 1,010,000 | 120,000 | 4,055,000 |
| ● អ្នកជាប់ពន្ធធំ / Large taxpayer | 1,500,000 | 400,000 | 25,000 | 1,010,000 | 120,000 | 3,055,000 |
| ● អ្នកជាប់ពន្ធមធ្យម / Medium taxpayer | 600,000 | 400,000 | 25,000 | 1,010,000 | 120,000 | 2,155,000 |
| ● អ្នកជាប់ពន្ធតូច / Small taxpayer | 200,000 | 20,000 | 25,000 | 1,010,000 | 120,000 | 1,375,000 |
| **P5- សហគ្រាសឯកបុគ្គល និងបុគ្គលប្រកបអាជីវកម្មដទៃទៀត** Sole Proprietorship / Others | | | | | | |
| ● អ្នកជាប់ពន្ធធំមានផលរបរលើសពី ១០ ពាន់លានរៀល/ឆ្នាំ / Large taxpayer turnover more than 10,000 Million KHR/year | 2,500,000 | 400,000 | 25,000 | 180,000 | 120,000 | 3,225,000 |
| ● អ្នកជាប់ពន្ធធំ / Large taxpayer | 1,500,000 | 400,000 | 25,000 | 180,000 | 120,000 | 2,225,000 |
| ● អ្នកជាប់ពន្ធមធ្យម / Medium taxpayer | 600,000 | 400,000 | 25,000 | 180,000 | 120,000 | 1,325,000 |
| ● អ្នកជាប់ពន្ធតូច / Small taxpayer | 200,000 | 20,000 | 25,000 | 180,000 | 120,000 | 545,000 |

**សម្គាល់៖ Note:**

* បុគ្គលប្រកបអាជីវកម្មដទៃទៀត ដែលមានផលរបរតិចជាង ២៥០ លានរៀល/ឆ្នាំ មានកាតព្វកិច្ចចុះបញ្ជីពន្ធដារ និងត្រូវបង់តែកម្រៃសេវាចុះបញ្ជីពន្ធដារ ២០ ០០០រៀល។
Any person who carrying out business activity with a turnover of less than 250 Million KHR/year has the obligation to apply for registration and shall pay only a tax registration fee of 20,000 KHR.

* កម្រៃសេវាធ្វើបច្ចុប្បន្នភាពព័ត៌មាន នៅរដ្ឋបាលសារពើពន្ធ៖
Information update fee at tax administration:

- បោះពុម្ពប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ ៥ ០០០ រៀល / Tax identification card printing fee 5,000 KHR
- អ្នកជាប់ពន្ធមធ្យម-ធំ ២០០ ០០០ រៀល / Medium and large taxpayer 200,000 KHR
- អ្នកជាប់ពន្ធតូច និងអ្នកជាប់ពន្ធដទៃទៀត ១០ ០០០ រៀល / Small taxpayer and others 10,000 KHR

#### ៣.២.៤ រយៈពេល ទទួលបានការចុះបញ្ជី និងការធ្វើបច្ចុប្បន្នភាព

រយៈពេលផ្តល់សេវា និងឯកសារត្រូវទទួលបាន៖

- ៧ ទៅ១០ថ្ងៃ នៃថ្ងៃធ្វើការ (គិតចាប់ពីថ្ងៃចេញលិខិតបញ្ជាក់ការទទួលពាក្យស្នើរសុំ) ចំពោះស្ថាប័នរដ្ឋ បេសកម្មទូត កុងស៊ុលបរទេស អង្គការអន្តរជាតិ ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេស របស់រដ្ឋាភិបាលនានា គណបក្សនយោបាយ សមាគម និងអង្គការមិនមេនរដ្ឋាភិបាល ឬបុគ្គលដទៃទៀតដែលមិនតម្រូវឬមិនអាចបញ្ចូលព័ត៌មានទៅក្នុងគេហទំព័រចុះបញ្ជីអាជីវកម្ម ។
- ៧ ទៅ១០ថ្ងៃ នៃថ្ងៃធ្វើការ( គិតចាប់ពីថ្ងៃ ចេញលិខិតបញ្ជាក់ការទទួលពាក្យស្នើសុំ ក្រោយទទួលបានលិខិតជាសារអេឡិចត្រូនិច បញ្ជាក់ការទទួលពាក្យស្នើសុំពីគេហទំព័រចុះបញ្ជីអាជីវកម្ម)ចំពោះសហគ្រាសពាណិជ្ជកម្មដែលស្នើសុំចុះបញ្ជីថ្មី។

## ៣.៣ អត្ថប្រយោជន៍នៃការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធ

#### ៣.៣.១ ការចុះពិនិត្យស្ថានភាពអាជីវកម្ម

ក្នុងករណី ដែលរដ្ឋបាលសារពើពន្ធពិនិត្យឃើញថា ព័ត៌មាននៃការចុះបញ្ជីរបស់អ្នកជាប់ពន្ធមិនច្បាស់លាស់ មិនគ្រប់ជ្រុងជ្រោយរដ្ឋបាលសារពើពន្ធអាចចុះពិនិត្យស្ថានភាពអាជីវកម្ម ដល់ទីតាំងរបស់អ្នកជាប់ពន្ធ ឬអញ្ជើញប្រធាន ក្រុមប្រឹក្សាភិបាល ម្ចាស់សហគ្រាស ឬប្រធានសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលជាអ្នកត្រូវទទួលបន្ទុក កិច្ចការពន្ធដារមកផ្តល់ព័ត៌មាន ផ្តល់ឯកសារពាក់ព័ន្ធនានា ឬធ្វើការផ្ទៀងផ្ទាត់អត្តសញ្ញាណ ដោយការចុះហត្ថលេខា ការថតរូបស្កែនម្រាមដៃ និងប្រឹក្សាយោបល់ពាក់ព័ន្ធនឹងច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ ដោយផ្ទាល់នៅរដ្ឋបាលសារពើពន្ធ ឬតាមមធ្យោបាយបច្ចេកវិទ្យាព័ត៌មានផ្សេងៗទៀត។

ក្នុងករណី ដែលប្រធានក្រុមប្រឹក្សាភិបាល ម្ចាស់សហគ្រាស ប្រធានសមាគម និងអង្គការមិនមែនរដ្ឋាភិបាលណាមួយមិនអាចអញ្ជើញមកបង្ហាញខ្លួន ដោយផ្ទាល់នៅរដ្ឋបាលសារពើពន្ធបានត្រូវធ្វើលិខិតផ្ទេរសិទ្ធិឱ្យអ្នកតំណាងណាមួយ នៅក្នុងក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ឬសមាគម និងអង្គការមិនមែនរដ្ឋាភិបាលដែលបានទទួលស្គាល់ដោយក្រសួង ឬស្ថាប័នមានសមត្ថកិច្ចមកបំពេញកាតព្វកិច្ចជំនួសខ្លួនបាន ឬក្នុងករណីចាំបាច់ អាចស្នើសុំឱ្យរដ្ឋបាលសារពើពន្ធផ្តល់សេវាទៅថតរូប-ស្កេនស្នាមម្រាមដៃទៅដល់ទីតាំងសហគ្រាស ឬទីកន្លែងសមស្របណាមួយ។

#### ៣.៣.២ ការបដិសេធការស្នើសុំចុះបញ្ជីពន្ធដារ និងបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ

ក្នុងករណី បុគ្គលណាមួយដែលបានដាក់ពាក្យស្នើសុំចុះបញ្ជីពន្ធដារ និងបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ ដូចមានចែងក្នុងប្រការ៤ និងប្រការ៥ នៃប្រកាសមិនបានបំពេញព័ត៌មាន និងផ្តល់ឯកសារភ្ជាប់ឱ្យបានត្រឹមត្រូវ ឬមិនគោរពតាមលក្ខខណ្ឌតាមការតម្រូវរបស់រដ្ឋបាលសារពើពន្ធ ឬជាប់ទាក់ទិននឹងសហគ្រាស ឬសមាគម ឬអង្គការនានា ដទៃទៀតដែលមានជំពាក់បំណុលពន្ធ ឬមិនមានទីលំនៅ ឬកន្លែងធ្វើអាជីវកម្មជាប់លាប់ ឬកន្លែងធ្វើសកម្មភាព អាជីវកម្មមិនសមស្របនឹងកម្មវត្ថុអាជីវកម្មដែលបានស្នើសុំ រដ្ឋបាលសារពើពន្ធមានសិទ្ធិបដិសេធការស្នើសុំចុះបញ្ជីពន្ធដារ និងបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ ដោយត្រូវជូនដំណឹងជា

លាយលក្ខណ៍អក្សរដល់អ្នកជាប់ពន្ធ ស្តីពីការបដិសេធចំពោះការស្នើសុំចុះបញ្ជីពន្ធដារ និងបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធក្នុងអំឡុងពេល ៣០ ថ្ងៃយ៉ាងយូរ។

### ៣.៣.៣ ការចុះបញ្ជីជាឯកតោភាគី និងបញ្ជីអវិជ្ជមានសម្រាប់ការចុះបញ្ជី

#### ក. ការចុះបញ្ជីពន្ធដារឯកតោភាគី

បុគ្គលទាំងឡាយ ដែលច្បាប់បានកំណត់ឱ្យចុះបញ្ជីហើយបានមកចុះបញ្ជី ឬមិនបានមកចុះបញ្ជីតាមការអញ្ជើញរបស់រដ្ឋបាលសារពើពន្ធ រដ្ឋបាលសារពើពន្ធមានសិទ្ធិចុះបញ្ជីអ្នកជាប់ពន្ធជាឯកតោភាគី។ ក្នុងករណីនេះ រដ្ឋបាលសារពើពន្ធអាចកំណត់កាលបរិច្ឆេទមានប្រសិទ្ធភាពនៃការចុះបញ្ជី និងកំណត់នូវអ្នកតំណាងណាមួយរបស់សហគ្រាស ដើម្បីទទួលបន្ទុកកិច្ចការពន្ធដារ។

#### ខ. បញ្ជីអវិជ្ជមានសម្រាប់ការចុះបញ្ជី

អគ្គនាយកដ្ឋានពន្ធដារ ត្រូវរៀបចំបញ្ជីអវិជ្ជមានសម្រាប់ការចុះបញ្ជី សម្រាប់កត់ត្រាអត្តសញ្ញាណរបស់បុគ្គលណាមួយដែល៖

ក. ជាប់ទាក់ទិននឹងសហគ្រាស សមាគម ឬអង្គការនានា ដទៃទៀតដែលត្រូវបានអគ្គនាយកដ្ឋានពន្ធដារ បដិសេធចំពោះការស្នើសុំចុះបញ្ជីពន្ធដារ ដើម្បីបង្កើតសហគ្រាស ឬសមាគម ឬអង្គការនានាដទៃទៀតក្នុងគោលបំណងប្រព្រឹត្តិបទល្មើសគេចវេះពន្ធ។

ខ. មានជំពាក់បំណុលពន្ធ ឬជាប់ទាក់ទិននឹងសហគ្រាស សមាគម ឬអង្គការនានាដទៃទៀតដែលមានជំពាក់បំណុលពន្ធ។

គ. ខកខានក្នុងការមកបង្ហាញខ្លួនផ្តល់ព័ត៌មានបន្ថែម និងផ្តល់ឯកសារជម្រូវនានាតាមការអញ្ជើញរបស់រដ្ឋបាលសារពើពន្ធ។

ឃ. ជាប់ទាក់ទិននឹងសហគ្រាស សមាគម ឬអង្គការនានាដទៃទៀតដែលត្រូវបានអគ្គនាយកដ្ឋានពន្ធដារចុះបញ្ជីជាឯកតោភាគី ហើយមិនបានផ្តល់កិច្ចសហការបំពេញព័ត៌មាន និងផ្តល់ឯកសារតម្រូវសម្រាប់ការចុះបញ្ជីពន្ធដារឱ្យបានចប់សព្វគ្រប់។

ង. រដ្ឋបាលសារពើពន្ធ មានមូលដ្ឋានច្បាស់លាស់ជឿជាក់ថា មិនមែនជាបុគ្គលដែលទទួលផលពិតប្រាដកពីអាជីវកម្ម ឬប្រព្រឹត្តបទល្មើសដោយផ្ទាល់ ឬមានចេតនាផ្តល់ពិនិត ឬជំរុញជួយជ្រោមជ្រែង ឬអូសទាញអ្នកជាប់ពន្ធ ឬបុគ្គលម្នាក់ទៀត ឱ្យប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ឬបទល្មើសសម្អាតប្រាក់ឬហិរញ្ញប្បទានភេរវកម្ម។

២-អគ្គនាយកដ្ឋានពន្ធដារ ត្រូវចែករំលែកបញ្ជីអវិជ្ជមានសម្រាប់ការចុះបញ្ជីដល់ក្រសួង-ស្ថាប័នមានសមត្ថកិច្ច តាមរយៈផ្លាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (Cambodia Data Exchange - CamDX) សម្រាប់ជាកម្មវត្ថុនៃការចូលរួមសហការក្នុងការពិនិត្យ និងសម្រេចផ្តល់ការអនុញ្ញាតចំពោះការស្នើសុំចុះបញ្ជី។

៣-បុគ្គលដែលត្រូវបានដាក់ចូលក្នុងបញ្ជីអវិជ្ជមាន នៃការចុះបញ្ជីរបស់អគ្គនាយកដ្ឋានពន្ធដារ នឹងមិនត្រូវបានអនុញ្ញាត ឱ្យចុះបញ្ជីអាជីវកម្មដទៃទៀតតាមគេហទំព័រចុះបញ្ជីអាជីវកម្មឡើយ លើកលែងតែបុគ្គលនោះបាន ដោះស្រាយរួចរាល់នូវកាតព្វកិច្ចសារពើពន្ធជាមួយនឹងអគ្គនាយកដ្ឋានពន្ធដារ។

### ៣.៣.៤ អត្ថប្រយោជន៍នៃការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធ

ការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធ មានសារៈសំខាន់ដូចជា៖

- ទទួលបាននូវការរក្សាទុកជាការសម្ងាត់ និងត្រូវបានយកមកប្រើប្រាស់ តែក្នុងគោលដៅដែលមានបញ្ជាក់នៅក្នុងបទប្បញ្ញត្តិស្តីពី ពន្ធដារនូវព័ត៌មាននានា ទាក់ទិននឹងកិច្ចការអាជីវកម្មរបស់ខ្លួន ដែលបានផ្តល់ឱ្យរដ្ឋបាលសារពើពន្ធដូចមានចែងក្នុងមាត្រា១៩៧នៃច្បាប់នេះ។
- ទទួលព័ត៌មានជាប្រចាំអំពីកិច្ចដំណើរការនៃប្រព័ន្ធពន្ធដារ និងនីតិវិធីនៃការកំណត់ពន្ធដូចមានចែងក្នុងមាត្រា១៩៩ និងមាត្រា២១១នៃច្បាប់នេះ។
- ទទួលព័ត៌មានអំពីសិទ្ធិរបស់ខ្លួន រួមទាំងសិទ្ធិក្នុងការប្តឹងតវ៉ា ដូចមានចែងក្នុងមាត្រា២១១ និងមាត្រា២៣៨ នៃច្បាប់នេះ។
- ប្តឹងតវ៉ាដូចមានចែងក្នុងច្បាប់នេះ ចំពោះរាល់សេចក្តីសម្រេចរបស់រដ្ឋបាលសារពើពន្ធដូចមានចែងក្នុងមាត្រា២១១ និងមាត្រា២៣៨ នៃច្បាប់នេះ។
- បង់ពន្ធ មិនឱ្យលើសពីបទប្បញ្ញត្តិស្តីពីពន្ធដារកំណត់ ។
- មានការទទួលស្គាល់តំណាងស្របច្បាប់របស់អ្នកជាប់ពន្ធ តាមការជ្រើសរើសដើម្បីផ្តល់យោបល់អំពីកិច្ចការសារពើពន្ធ។
- ទទួលបានការអនុវត្តដោយមានតម្លាភាព និងមិនលម្អៀងពីសំណាក់រដ្ឋបាលសារពើពន្ធ។
- ទទួលបានការទទួលស្គាល់ អំពីភាពស្មោះត្រង់ក្នុងការអនុវត្តកាតព្វកិច្ចសារពើពន្ធ។
- ទទួលបានការគាំពារតាមផ្លូវច្បាប់ ជៀសវាងការប្រឈមនឹងការផាកពិន័យផ្សេងៗ និងការតម្រូវឱ្យបិទទ្វារអាជីវកម្ម ក្នុងករណីដែលអាជ្ញាធរមានសមត្ថកិច្ចចុះអង្កេត អំពីភាពត្រឹមត្រូវនិងស្របច្បាប់នៃការប្រព្រឹត្តទៅនៃអាជីវកម្ម។
- ទាក់ទាញអតិថិជន និងដៃគូអាជីវកម្មជាពិសេសក្រុមហ៊ុនធំៗដែលធ្វើការបញ្ជាទិញក្នុងទំហំធំ និងមានតម្រូវការបរិមាណច្រើន ដោយធ្វើការបង្កើននូវភាពជឿជាក់ និងទំនុកចិត្តដែលទទួលបានពីភាពស្របច្បាប់នៃអាជីវកម្ម ព្រោះមិនមានក្រុមហ៊ុនធំណា មានបំណងចង់ធ្វើអាជីវកម្មជាមួយដៃគូអាជីវកម្មដែលមិនបានចុះបញ្ជីនោះទេ។
- បង្កភាពងាយស្រួល ក្នុងការទទួលបានហិរញ្ញប្បទាន៖ ធនាគារ និងវិនិយោគិនមានភាពជឿជាក់ក្នុងការផ្តល់ហិរញ្ញប្បទាន ចំពោះក្រុមហ៊ុនដែលចុះឈ្មោះជាងក្រុមហ៊ុនដែលមិនបានចុះបញ្ជី។
- សិទ្ធចូលក្នុងទីផ្សារធំៗ៖ អ្នកអាចទទួលបានអតិថិជនច្រើន បង្កើតភាពជាដៃគូរជាមួយក្រុមហ៊ុនដទៃ និងពង្រីកអាជីវកម្មរបស់អ្នក។ ឧទាហរណ៍ ក្រុមហ៊ុនមួយចំនួនសហការ និងចុះកិច្ចសន្យាជាមួយក្រុមហ៊ុនដៃគូរណា ដែលបានចុះបញ្ជីពាណិជ្ជកម្ម ត្រឹមត្រូវតាមនីតិវិធីច្បាប់តែប៉ុណ្ណោះ។
- គោលបំណងពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការចុះបញ្ជីពន្ធដារ និងការគ្រប់គ្រងទិន្នន័យរបស់អ្នកជាប់ពន្ធ ដើម្បីគាំទ្រដល់ការផ្តល់សេវាដល់អ្នកជាប់ពន្ធ និងការគ្រប់គ្រងការប្រមូលពន្ធឱ្យកាន់តែមានតម្លាភាព និងប្រសិទ្ធភាព។

# ជំពូកទី៤
# ការវិភាគចំណុចខ្លាំង និងចំណុចខ្សោយ

# ជំពូកទី៤
# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

បន្ទាប់ពីបានសិក្សាស្រាវជ្រាវទៅលើការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធរួចមក ក្រុមយើងខ្ញុំបានធ្វើស្រាវជ្រាវក្នុងការវិភាគស្វែងយល់ និងវាយតម្លៃលើចំណុចខ្លាំង និងចំណុចខ្សោយដូចខាងក្រោម៖

## ៤.១ ការវិភាគលើចំណុចខ្លាំង

- កាត់បន្ថយការគេចវេសពីការបង់ពន្ធ
- ពង្រឹង និងបង្កើនការគ្រប់គ្រងឱ្យបានកាន់តែប្រសើរឡើងនូវទិន្នន័យរបស់អ្នកជាប់ពន្ធ
- ធ្វើឱ្យការប្រមូលពន្ធមានការកើនឡើង ក្នុងជួយធ្វើឱ្យប្រទេសមានការអភិវឌ្ឍន៍
- កាត់បន្ថយការស៊ីសំណូក
- ជួយពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូលពន្ធ
- ទទួលបានការអនុវត្តនដោយមានតម្លាភាព និងមិនលម្អៀងពីសំណាក់រដ្ឋបាលសារពើពន្ធ
- មានផ្តល់នូវសេវាសមស្របដល់អ្នកជាប់ពន្ធរួមមាន ការផ្តល់ព័ត៌មានអប់រំ ចំណេះដឹងការ ពន្យល់ណែនាំដែលទាក់ទងនឹងពន្ធផ្សេងៗឱ្យអ្នកជាប់ពន្ធកាន់តែយល់ច្បាស់ និងពេញចិត្តដោយស្មោះត្រង់
- ការចុះដល់ទីតាំងផ្ទាល់ក្នុងករណី ដែលរដ្ឋបាលសារពើពន្ធពិនិត្យឃើញថា ព័ត៌មាននៃការចុះបញ្ជីរបស់អ្នកជាប់ពន្ធមិនច្បាស់លាស់ មិនគ្រប់ជ្រុងជ្រោយ
- អគ្គនាយកដ្ឋានពន្ធដារ ត្រូវរៀបចំបញ្ជីអវិជ្ជមានសម្រាប់ការចុះបញ្ជី សម្រាប់កត់ត្រាអត្តសញ្ញាណរបស់បុគ្គលណាដែលប្រព្រឹត្តខុសច្បាប់។

## ៤.២ ការវិភាគលើចំណុចខ្សោយ

ទន្ទឹមនឹងចំណុចខ្លាំង ដែលបានរៀបរាប់ខាងលើ យោងតាមការស្រាវជ្រាវយើងសង្កេតឃើញថា ពន្ធដារ ក៏មានចំណុចខ្សោយមួយចំនួនផងដែលរួមមាន៖

- ការអនុវត្តលើការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់មិនសូវមានភាពសកម្ម និងមានភាពយឺតយ៉ាវ
- ពលរដ្ឋមិនសូវមានការយល់ដឹងអំពីការបង់ពន្ធ
- មូលដ្ឋានទិន្នន័យអ្នកជាប់ពន្ធ (taxpayer database) មិនទាន់ត្រូវបានធ្វើបច្ចុប្បន្នភាពពេញលេញ
- ការផ្តល់សេវាដល់អ្នកជាប់ពន្ធនៅមានកម្រិត
- កង្វះផែនការយុទ្ធសាស្រ្តពីការផ្តល់សេវា និងការអប់រំរបស់អ្នកជាប់ពន្ធនៅកម្រិតថ្នាក់កណ្តាល និងសាខាខេត្ត-ខណ្ឌ ។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ៥.១ សេចក្តីសន្និដ្ឋាន

យោងតាមការសិក្សាស្រាវជ្រាវទៅលើប្រធានបទ" **ការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធសាខាខ្ទួលគោក** " យើងបានសង្កេតឃើញថា ការធ្វើបច្ចុប្បន្នភាពពិតជាមានសារៈសំខាន់ណាស់ ក្នុងការជួយជម្រុញឱ្យយុទ្ធសាស្ត្រប្រមូលពន្ធរបស់រដ្ឋឱ្យមានប្រសិទ្ធភាព និងជួយដល់ការដោះស្រាយបញ្ហាសេដ្ឋកិច្ចផងដែរ។ ម្យ៉ាងវិញទៀត ដំណើរការនៃការធ្វើបច្ចុប្បន្នភាព ក៏បានជួយជម្រុញក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធប្រទេសជាតិឱ្យកាន់តែរីកចម្រើន ដូចជា៖ ស្ពានថ្នល់ សាលារៀន មន្ទីពេទ្យ... ។ល។ ដូចគ្នានេះដែរ ការធ្វើបច្ចុប្បន្នភាព ក៏បានជួយជម្រុញឱ្យសហគ្រាសមានការយល់ដឹងអំពី កាតព្វកិច្ចក្នុងការបង់ពន្ធជូនរដ្ឋ ក៏ដូចជាការធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសរបស់ខ្លួន។

ទន្ទឹមនឹងនេះផងដែល ការធ្វើបច្ចុប្បន្នភាពព័ត៌មានរបស់អ្នកជាប់ពន្ធ ក៏មានចំណែកក្នុងការជួយឱ្យមានការយល់ដឹងពីសិទ្ធិរបស់អ្នកជាប់ពន្ធ ទៅដល់ប្រជាពលរដ្ឋ ក៏ដូចជាជួយពង្រឹងដល់ការចុះបញ្ជី និងទិន្នន័យរបស់អ្នកជាប់ពន្ធផងដែរ។ ក្នុងដំណើរការនៃការធ្វើបច្ចុប្បន្នភាពនេះដែល នាយកដ្ឋានពន្ធក៏បានចូលរួមចំណែកយ៉ាងសកម្ម និងបានយកចិត្តទុកដាក់យ៉ាងខ្ពស់ ក្នុងការជួយជ្រោមជ្រែងដល់ការអនុវត្តច្បាប់ ក៏ដូចជាប្រកាសដែលបានចេញផ្សាយ ដើម្បីបញ្ជាក់ពីគោលជំហររបស់ខ្លួនក្នុងកាតព្វកិច្ច ចំពោះការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធទាំងអស់។ រាល់សហគ្រាសទាំងអស់ ដែលកំពុងប្រកបអាជីវកម្ម ត្រូវគោរពតាមបទបញ្ញត្តិនានា ដែលមានចែងនៅក្នុងច្បាប់សារពើពន្ធនៃប្រទេសកម្ពុជា។ យ៉ាងណាមិញ យើងសង្កេតឃើញថា ក្នុងការធ្វើបច្ចុប្បន្នភាពរបស់សហគ្រាសនីមួយៗ នៅតែមានឧបសគ្គមួយចំនួនដែលបង្ករដល់ការរាំងស្ទះដល់ការអនុវត្តច្បាប់ ពោលគឺសហគ្រាសពុំសូវយល់ដឹងពីការធ្វើបច្ចុប្បន្នភាព និងការគេចវេសពីការបង់ពន្ធជាដើម។ តែទោះជាយ៉ាងនេះក្តី អគ្គនាយកដ្ឋានពន្ធដារ បានព្យាយាមផ្សព្វផ្សាយ ពន្យល់ណែនាំ ពីការចុះបញ្ជី ក៏ដូចជាការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធ ដល់អ្នកជាប់ពន្ធក៏ដូចជាពលរដ្ឋឱ្យយល់ដឹងពីការចុះបញ្ជី ការបង់ពន្ធ និងការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធឱ្យកាន់តែទូលំទូលាយផងដែរ។

សរុបសេក្តីមក ក្នុងបរិបទបច្ចុប្បន្ននេះការបំពេញកាតព្វកិច្ចពីសំណាក់អ្នកជាប់ពន្ធមានការយល់ដឹងកាន់ប្រសើរឡើងពីមួយឆ្នាំទៅមួយឆ្នាំ ទៅតាមរយៈការកែទម្រង់របស់ពន្ធដារ ក៏ដូចជាការចេញផ្សាយយ៉ាងទូលំទូលាយតាមប្រព័ន្ធផ្សេងៗ។

## ៥.២ ការផ្តល់អនុសាសន៍

ដោយផ្អែកទៅលើការសន្និដ្ឋាន និងការសិក្សាស្រាវជ្រាវកន្លងមក យើងអាចផ្តល់នូវយោបល់មួយចំនួនដើម្បីជម្រុញដល់ការចុះបញ្ជី និងការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធឱ្យកាន់តែប្រសើរ និងមានប្រសិទ្ធិភាពនោះក្រុមយើងខ្ញុំសូមផ្តល់នូវអនុសាសន៍មួយចំនួនដូចជា៖

- សូមជួយពង្រឹងការអនុវត្តច្បាប់នៃការចុះបញ្ជី និងការធ្វើបច្ចុប្បន្នភាព អ្នកជាប់ពន្ធឱ្យមានប្រសិទ្ធិភាពឱ្យកាន់តែប្រសើរ។

- សំណូមពរដល់មន្ត្រីមួយចំនួន ដែលបម្រើការងារ សូមប្រកាន់ភ្ជាប់នូវឥរិយាបថឱ្យបានសមរម្យ និងប្រកាន់ភ្ជាប់នូវក្រមសីលធម៌ និងសុជីវធម៌។
- សូមជួយផ្សព្វផ្សាយចំណេះដឹងនៃការបង់ពន្ធ ការចុះបញ្ជី និងការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធដល់ប្រជាពលរដ្ឋ ក៏ដូចជាសហគ្រាសឱ្យបានកាន់តែប្រសើរឡើង។
- សូមពង្រឹងសមត្ថភាពក្នុងការធ្វើសវនកម្មបន្ថែម ជៀសវាងការមានឯកសារក្លែងបន្លំផ្សេងៗ ពីស្ថាប័ន ឬក្រុមហ៊ុនមួយចំនួនដែលធ្វើឲ្យគ្មានភាពស្មោះត្រង់ ចំពោះការចុះបញ្ជី និងការធ្វើបច្ចុប្បន្នភាពព័ត៌មាន។
- ជួយពង្រឹងការផ្សព្វផ្សាយអំពីច្បាប់ពន្ធ ក៏ដូចជាបទប្បញ្ញត្តិស្ដីពីពន្ធដារឱ្យដល់ពលរដ្ឋ តាមបណ្ដាលខេត្តឱ្យបានច្រើនជាងមុន។

# ឯកសារយោង

# ឯកសារយោង


- វិទ្យាស្ថាន វ៉ាន់ដា សារណាសិស្សច្បងក្នុងបណ្ណាល័យនៃវិទ្យាស្ថានវ៉ាន់ដា ក្រោមប្រធានបទ ដំណើរការនៃការប្រមូលពន្ធកាត់ទុករបស់សាខាពន្ធដារខណ្ឌទួលគោក ទំព័រទី៥
- ច្បាប់ស្តីពីសារពើពន្ធ_២០២៣ (1).pdf'
- វិទ្យាស្ថាន វ៉ាន់ដា សារណាសិស្សច្បងក្នុងបណ្ណាល័យនៃវិទ្យាស្ថានវ៉ាន់ដា ក្រោមប្រធានបទ ដំណើរនៃការប្រមូលពន្ធលើអចលនទ្រព្យរបស់ពន្ធដារ សាខា៧មករា ទំព័រទី៨
- http://chandaracitc.weebly.com/uploads/1/3/0/1/13016555/taxationpdf.
- https://www.tax.gov.kh/km
- https://gs.mef.gov.kh/contents/uploads/2021/09/8%E1%9E%96%E1%9E%93%E1%9F%92%E1%9E%92%E1%9E%8A%E1%9E%B6%E1%9E%9A.pdf
- https://lorkremlaw.files.wordpress.com/2014/09/e19e80e19eb6e19e8fe19e96e19f92e19e9ce19e80e19eb7e19e85e19f92e19e85e19e93e19eb7e19e84e19e9fe19eb7e19e91e19f92e19e92e19eb7e19e9ae19e941.pdf
- Prakas-496-on-Tax-Registration-in-Khmer.pdf
- https://www.tax.gov.kh/(taxpayer)
- Prakas-on-Tax-Registration-and-Company-Update.pdf

# ឧបសម្ព័ន

# ឧបសម្ព័ន្ធ


ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
Ministry of Economy and Finance
អគ្គនាយកដ្ឋានពន្ធដារ
General Department of Taxation

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ...៩៦០៦..............សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការចុះបញ្ជីពន្ធដារ និងការធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ និងវិសោធនកម្មជាបន្តបន្ទាប់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ. បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន


ផ្ទះលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone : (+855)23 890 666